សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# សន្តតិកម្មតាមច្បាប់

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


រៀបរៀងដោយនិស្សិតៈ

និស្សិតឈ្មោះ **លោក កែវ ឧត្សាហមង្គល**

**លោកស្រី ម៉ុន ដាណា**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឧត្ដី**



ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៦ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ ឈ្មោះ **កែវ ទិត្យាមង្គល និង ម៉ុន ដាណា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រ ឆ្នាំទី ៤ ជំនាន់ទី ២៦ ថ្នាក់ អាហារូបករណ៍ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូន**

លោកមានគុណទាំងពីរ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំ ព្រមទាំងឧបត្ថម្ភគ្រប់បែបយ៉ាង ទាំងសម្ភារៈ និងស្មារតី ជាពិសេសលោកទាំងពីរបានលើកទឹកចិត្តកូន ឲ្យចេះតស៊ូក្នុងការសិក្សារៀនសូត្រ ទើបពួកកូន មានថ្ងៃនេះ ជាថ្ងៃដែលកូនៗមានកិត្តិយស និងមានមោទនភាពបំផុត ដែលកូនបានសិក្សាទទួលបានពិន្ទុល្អ ហើយត្រូវបានសាលា អនុញ្ញាតឲ្យពួកយើងខ្ញុំបានសរសេរសារណា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងបានការពារនូវស្នាដៃដែលពួក កូនបានធ្វើការស្រាវជ្រាវ ផ្នែក នីតិសាស្ត្រ នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលទទួលបានលទ្ធផលប្រកបដោយជោគជ័យជាស្ថាពរ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះ លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ លើគ្រប់មុខវិជ្ជាចាប់ពីឆ្នាំទី ១ ដល់ ឆ្នាំទី ៤ ដែលពួកគាត់តែងតែចំណាយអស់នូវកម្លាំងកាយ ចិត្ត ស្មារតី និងបញ្ចេញអស់នូវចំណេះដឹង បទពិសោធន៍ និងទេពកោសល្យគ្រប់បែបយ៉ាង ដើម្បីឲ្យនិស្សិតបានចេះដឹង ប្រកបដោយកិត្តិយសថ្លៃថ្នូរ។

ជាងនេះទៅទៀតយើងខ្ញុំក៏សូមថ្លែងអំណរគុណ ចំពោះឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ប្រធានការិយាល័យ និងបុគ្គលិកមន្ត្រីរាជការទាំងអស់ ដែលលោក អ្នកទាំងបានខិតខំ បំពេញភារកិច្ច និងបានផ្តល់សេវាដ៏ល្អ ដែលជាឱកាសដ៏ប្រពៃដើម្បីឲ្យយើងខ្ញុំ អាចសម្រេចនូវគោលដៅក្នុងការសិក្សានៅទីនេះប្រកបដោយលក្ខណៈងាយស្រួល។

ជាពិសេសយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកសាស្ត្រាចារ្យ **ញឹក ឧុធី** ដែលលោកបានចំណាយអស់នូវកំលាំងកាយ កំលាំងចិត្ត ប្រាជ្ញាស្មារតី និងរិះរកវិធីសាស្ត្របង្រៀនល្អៗ ងាយយល់ ប្រកបដោយទេសកោសល្យក្នុងការបង្រៀនដល់និស្សិត ដែលនាំពួកគេទទួលបាននូវ ចំណេះដឹងមួយពិតប្រាកដ ដែលជាធនធានមនុស្សពិតៗ ដើម្បីកសាងប្រទេសជាតិ និងអភិវឌ្ឍន៍ខ្លួននាពេលអនាគត។

ជាទីបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរជ័យ ដល់ឯកឧត្តម លោក-លោកស្រី សាស្ត្រាចារ្យ និងអ្នកមានគុណទាំងអស់ជួបប្រទះនូវពុទ្ធពរ ទាំងបួនប្រការ គឺវណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លាតឃ្លាឡើយ។

..................................

## អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកច្បាប់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានសេចក្តីសោមនស្ស រីករាយយ៉ាងក្រៃលែង ដែលមានឱកាសបានសរសេរសារណាបញ្ចប់ការសិក្សា ក្រោយពីបានសិក្សាអស់រយៈពេល ៤ឆ្នាំកន្លងមកនេះ ហើយយើងខ្ញុំក៏បានជ្រើសយកនូវប្រធានបទស្តីពី **សន្តតិកម្មតាមច្បាប់** មកធ្វើការតាក់តែងឡើង។ ការលើកយក ប្រធានបទស្តីពី សន្តតិកម្មតាមច្បាប់ មកធ្វើការស្រាវជ្រាវ ក្នុងបំណងពង្រីកចំណេះដឹងផ្នែកនេះឲ្យកាន់តែស៊ីជម្រៅ ពីព្រោះ បញ្ហាបច្ចុប្បន្នភាព នៅក្នុងជីវភាពជាក់ស្តែងគឺបញ្ហាវិវាទឈ្លោះប្រកែកគ្នា តែពីរឿងមត៌ក ដែលបន្សល់ពីមតកជន ដែលមិនបានធ្វើតាមបណ្តាំទុកឲ្យសន្តតិជនរបស់អ្នកស្លាប់។ ម្យ៉ាងវិញទៀតដោយយល់ឃើញថា គ្រួសារណាក៏ដោយក៏តែងតែមាននូវបញ្ហាជៀសមិនផុតឡើយ ជាពិសេសគឺទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់បុគ្គលដែលបានស្លាប់ទៅ។ ហេតុដូច្នេះហើយការសិក្សាអំពីប្រធានបទនេះពិតជាមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់អ្នកច្បាប់ដើម្បីចូលរួមក្នុងការដោះស្រាយជម្លោះគ្រួសារក្នុងសង្គម។ គួររំលឹកផងដែរថា នៅក្នុងប្រទេសកម្ពុជា របបសន្តតិកម្ម កើតមានតាំងពីយូរយាណាស់មកហើយ ក្នុងរូបភាពជាការអនុវត្តតៗគ្នា។ រហូតមកដល់ឆ្នាំ ១៩២០ ទើបប្រទេសកម្ពុជាមានក្រមរដ្ឋប្បវេណី ដើម្បីធ្វើការគ្រប់គ្រងទៅលើនីតិឯកជន។ ទោះបីជាយ៉ាងនេះ ក៏ការគ្រប់គ្រងទៅលើរបបនៃសន្តតិកម្ម ចំពោះការបែងចែកមត៌ក ពុំទាន់មានភាពត្រឹមត្រូវនោះទេ ព្រោះច្បាប់នាសម័យនោះនៅមានភាពរើសអើងទៅលើស្ត្រី ព្រមទាំងកូនមួយចំនួន រហូតដល់ឆ្នាំ ២០០៧ ទើបលេចឡើងនូវក្រមរដ្ឋប្បវេណីថ្មីដែលស្របតាមបច្ចុប្បន្នភាពរបស់សង្គម។

នៅក្នុងអត្ថបទស្រាវជ្រាវមួយនេះ យើងខ្ញុំទាំងពីរនាក់បានចំណាយពេលវេលាយ៉ាងច្រើននៅក្នុងការស្វែងរកឯកសារពាក់ព័ន្ធផ្សេងៗ ដែលមានស្រាប់ នៅតាមបណ្ណាល័យ ដូចជា ឯកសារច្បាប់ ឯកសារមេរៀន និងធ្វើការស្រាវជ្រាវតាមប្រព័ន្ធ អ៊ីនធឺណេត ឬគេហទំព័រផ្សេងៗ ដើម្បីប្រមូលបានជាទិន្នន័យក្នុងការចងក្រងជាសៀវភៅសារណានេះឡើង។ យើងខ្ញុំសង្ឃឹមថា សារណាមួយនេះ នឹងជាគុណប្រយោជន៍មួយចំណែកតូច ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវបន្ថែមទៀត សំរាប់និស្សិតជំនាន់ក្រោយៗ ដែលមានបំណងចង់ស្វែងយល់អំពីរបបសន្តតិកម្មនេះឲ្យកាន់តែស៊ីជម្រៅឡើង។

យ៉ាងណាមិញ ខ្ញុំជឿជាក់ថា សារណាមួយនេះនៅមានចំណុចខ្វះខាតនៅឡើយ ដែលកើតមានឡើងដោយអចេតនា តាមរយៈកំហុសអក្ខរាវិរុទ្ធ ការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យក៏ដូចជាកង្វះខាតផ្នែកអត្ថន័យក្តី ហេតុនេះហើយប្រសិនបើមានចំណុចខ្វះខាតត្រង់ចំណុចណាមួយ យើងខ្ញុំក៏សូមខន្តី អភ័យទោស រាល់ចំណុចខ្វះខាតទាំងនោះ និងរីករាយចំពោះការរិះគន់ទាំងឡាយ នៅក្នុងគោលបំណងដើម្បីស្ថាបនា ឲ្យកាន់តែមានភាពល្អប្រសើរឡើង ហើយក៏រងចាំទទួលរាល់ការកែលម្អឡើងវិញពីសំណាក់សាស្ត្រាចារ្យ សិស្ស និស្សិត មិត្តអ្នកអាន ដោយក្តី សោមនស្សរីករាយផងដែរ។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ............ ១

**ជំពូកទី ១**

**ទិដ្ឋភាពទូទៅនៃសន្តតិកម្មតាមច្បាប់**

**ផ្នែកទី ១៖ របបនៃសន្តតិកម្មក្នុងប្រទេសកម្ពុជា** ............ ៤

**កថាភាគទី ១៖ មូលដ្ឋាននៃប្រព័ន្ធសន្តតិកម្ម** ............ ៤

១. តើសន្តតិកម្មជាអ្វី? ............ ៤

២. សិទ្ធិ និងកាតព្វកិច្ចលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្ម ............ ៤

**កថាភាគទី ២៖ សន្តតិកម្មតាមច្បាប់** ............ ៥

១. ស្ថានភាពជាក់ស្តែងនៃសន្តតិកម្ម ............ ៥

២. វិធីបែងចែកមត៌ក ............ ៥

ក.តាមការពិភាក្សា ............ ៥

ខ.តាមផ្លូវតុលាការ ............ ៦

**ផ្នែកទី ២៖ លក្ខណៈសម្បត្តិនៃការទទួលបាន និងកាត់ផ្តាច់សិទ្ធិជាសន្តតិជន** ............ ៦

**កថាភាគទី ១៖ លក្ខខណ្ឌនៃការទទួលបានសិទ្ធិជាសន្តតិជន** ............ ៦

១. ករណីសន្តតិជនស្ថិតក្នុងស្ថានភាពជាទារកក្នុងគភ៌ ............ ៦

២. ករណីសន្តតិជនជារូបវន្តបុគ្គល ............ ៧

**កថាភាគទី ២៖ លក្ខខណ្ឌនៃការផ្តាច់សិទ្ធិជាសន្តតិជន** ............ ៨

១. ករណីអភ័ព្វបុគ្គល ............ ៨

២. ករណីបុគ្គលត្រូវបានផ្តាច់ពីមត៌ក ............ ៩

**ផ្នែកទី ៣៖ អានុភាពនៃសន្តតិកម្មតាមច្បាប់** ............ ១០

**កថាភាគទី ១៖ ពេលវេលាបើកសន្តតិកម្មតាមច្បាប់** ............ ១០

១. ករណីទទួលមរណភាព ............ ១០

២. ករណីបាត់ខ្លួន ............ ១០

**កថាភាគទី ២៖ ទីកន្លែងដែលអាចអនុវត្តនូវសន្តតិកម្ម** ............ ១១

## ជំពូកទី ២

## ការបែងចែកមត៌កតាមច្បាប់

**ផ្នែកទី ១៖ លក្ខណៈសម្បត្តិនៃសន្តតិជន** ........ ១២

**កថាភាគទី ១៖ ជនដែលត្រូវទទួលបានសន្តតិកម្ម** ........ ១២

១. សន្តតិជនលំដាប់ទី ១ ........ ១២

ក.ករណីសន្តតិជនលំដាប់ទី ១ នៅរស់ ........ ១២

ខ.ករណីសន្តតិជនលំដាប់ទី ១ ស្លាប់ ........ ១៣

២. សន្តតិជនលំដាប់ទី ២ ........ ១៥

៣. សន្តតិជនលំដាប់ទី ៣ ........ ១៥

៤. សន្តតិកម្មរបស់សហព័ទ្ធ ........ ១៦

**កថាភាគទី ២៖ ការសម្រួលចំណែកមត៌កនៃសន្តតិជន** ........ ១៦

១.ចំណែកមត៌កតាមច្បាប់ ........ ១៦

២.ផលប្រយោជន៍ពិសេស ........ ១៧

៣. ករណីមានប្រទានកម្ម ........ ២០

៤. ភាគនៃវិភាគទាន ........ ២២

**កថាភាគទី ៣៖ អ្នកទទួលមត៌កជាជនបរទេស** ........ ២៣

**ផ្នែកទី ២៖ សិទ្ធិ និងកាតព្វកិច្ចលើបំណុលនៃសន្តតិកម្ម** ........ ២៣

**កថាភាគទី ១៖ សិទ្ធិលើបំណុលនៃសន្តតិកម្ម** ........ ២៣

១. សិទ្ធិលើបំណុលដែលអាចបែងចែកបាន ........ ២៤

២. សិទ្ធិលើបំណុលអវិភាគីយ៍ ........ ២៤

**កថាភាគទី ២៖ កាតព្វកិច្ចលើបំណុលនៃសន្តតិកម្ម** ........ ២៤

១. កាតព្វកិច្ចលើបំណុលដែលអាចបែងចែកបាន ........ ២៤

២. កាតព្វកិច្ចលើបំណុលអវិភាគីយ៍ ........ ២៥

## ជំពូកទី ៣

## ការអនុវត្តសន្តតិកម្មតាមច្បាប់

**ផ្នែកទី ១៖ ការយល់ព្រម និងការបោះបង់នូវសន្តតិកម្ម** ........ ២៦

**កថាភាគទី ១៖ ការយល់ព្រម** ........ ២៦

១. ការយល់ព្រមទាំងស្រុង..........២៦
២. ការយល់ព្រមដោយមានកម្រិត..........២៧
**កថាភាគទី ២៖ ការបោះបង់**..........២៨
១.របៀបនៃការបោះបង់សន្តតិកម្ម..........២៨
ក.ការដាក់ពាក្យសុំ..........២៨
ខ.ករណីដែលសន្តតិជនជាអនីតិជន ឬជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ..........២៨
គ.ករណីដែលសន្តតិជនជាជននៅក្រោមហិតូបត្ថម្ភ..........២៨
២. ការដាក់កម្រិតរយៈពេលដាក់ពាក្យសុំ..........២៩
ក.ករណីសន្តតិជនទទួលមរណភាពដោយមិនបានយល់ព្រម ឬបោះបង់..........២៩
ខ.ករណីដែលសន្តតិជនជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ..........៣០
**កថាភាគទី ៣៖ អានុភាព**..........៣១
១.អានុភាពនៃការយល់ព្រមដោយកម្រិត..........៣១
២.អានុភាពនៃការបោះបង់..........៣២
**ផ្នែកទី ២៖ ភាគបម្រុង**..........៣២
**កថាភាគទី ១៖ ទិដ្ឋភាពទូទៅនៃភាគបម្រុង**..........៣២
១. ជនដែលមានសិទ្ធិលើភាគបម្រុង..........៣៤
២. ការកំណត់អំពីចំណែកនៃភាគបម្រុង..........៣៥
**កថាភាគទី ២៖ ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង**..........៣៦
១. ទ្រព្យដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង..........៣៦
២. លំដាប់នៃការកាត់បន្ថយ..........៣៨
**កថាភាគទី ៣៖ ការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយ**..........៤០
១.អាជ្ញាយុកាល..........៤០
២.ការបោះបង់ភាគបម្រុង..........៤១
**សេចក្តីសន្និដ្ឋាន**..........៤២
**អនុសាសន៍**..........៤៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅបណ្តាប្រទេសលើសកលលោក ពោរពេញទៅដោយរឿងរ៉ាវ ដែលបានកើតឡើងសុទ្ធតែមានបែបផែនខុសៗគ្នា តែអ្វីដែលពិសេសនោះគឺត្រូវតែមានដំណោះស្រាយដែលឈរលើគោលការណ៍ច្បាប់ជាធំ និងអាចអនុវត្តបានដើម្បីជាទំនុកចិត្តដល់ប្រជាពលរដ្ឋដែលបានគោរពលើសុក្រឹត្យភាពនៃគតិច្បាប់។ ក្នុងនោះជម្លោះនៅក្នុងគ្រួសារ ដែលបង្កឡើងជាបញ្ហានៃការបែងចែកមត៌កតែងតែកើតមានជាញឹកញាប់ក្នុងសង្គមខ្មែរ ទោះស្ថិតនៅក្នុងសម័យកាលណាក៏ដោយ ដែលជម្លោះនោះពេលខ្លះបានឈានទៅដល់ការកាប់សំលាប់គ្នាជាមួយបងប្អូនដោយសារតែការបែងចែកទ្រព្យសម្បត្តិរបស់ឪពុកម្តាយ ដែលបានស្លាប់ទៅ។ សកម្មភាពជម្លោះនេះផងដែរ មិនមែនតែទើបនឹងកើតមាននោះទេ ប៉ុន្តែបានកើតឡើងជាយូរលង់ណាស់មកហើយ ដោយសារតែបាតុភូតទាំងនេះហើយ ទើបគេបង្កើតឲ្យមានច្បាប់ផ្សេងៗ ដើម្បីជាមធ្យោបាយក្នុងការជួយធ្វើយ៉ាងណា កុំឲ្យបញ្ហាដែលកើតមានកន្លងមក កើតមាននៅពេលដែលការបែងចែកមត៌ករបស់ជនដែលបានស្លាប់ម្តងហើយម្តងទៀត នៅក្នុងសង្គមដែលជាហេតុផលដែលនាំឲ្យមានភាពអសន្តិសុខក្នុងការរស់នៅ។ នៅក្នុងការបង្កើតច្បាប់ដែលទាក់ទងទៅនិងមត៌កនេះទៀតសោត ត្រូវបានផ្លាស់ប្តូរទៅតាមសម័យកាលនីមួយៗ គឺធ្វើយ៉ាងណាឲ្យសមស្របទៅតាមការគ្រប់គ្រងរបស់ប្រទេសកម្ពុជា តួយ៉ាងកាលពីសម័យមុនព្រះមហាក្សត្រ គឺជាម្ចាស់លើដែនដីទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ សង្គមខ្មែរនាសម័យនោះមានការបែងចែកវណ្ណៈផ្សេងៗរួមមាន វណ្ណៈញាតិវង្សានុវង្ស (ក្សត្រ) សាសនា វណ្ណៈអ្នកមាន វណ្ណៈទាសីទាសា តាមរយៈការបែងចែកវណ្ណៈនេះ គឺឆ្លុះបញ្ចាំងឲ្យឃើញថាបុគ្គលម្នាក់ៗមានសិទ្ធិមិនដូចគ្នាទេ ជាពិសេសសិទ្ធិលើទ្រព្យសម្បត្តិឯកជន និងការធ្វើសន្តតិកម្មទៅឲ្យអ្នកជំនាន់ក្រោយ។ សម័យនោះប្រជារាស្ត្រមានសិទ្ធិត្រឹមតែសិទ្ធិភោគៈលើដីធ្លីពោលគឺ ពុំមានសិទ្ធិកម្មសិទ្ធិលើដីធ្លីនោះទេ ហើយត្រូវធ្វើសន្តតិកម្មនូវសិទ្ធិភោគៈ។ បន្ទាប់មក នាសម័យអាណានិគមនិយមបារាំង សិទ្ធិលើទ្រព្យសម្បត្តិឯកជនត្រូវបានផ្លាស់ប្តូរ ដោយសារបារាំងបាននាំយកនូវក្រមរដ្ឋប្បវេណីរបស់ខ្លួនមកកម្ពុជា (ក្រមរដ្ឋប្បវេណី ឆ្នាំ ១៩២០) ចាប់ពីពេលនោះមក កម្មសិទ្ធិឯកជនត្រូវលេចឡើងតាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០។ ចំណែកឯសម័យទទួលបានឯករាជ្យដែលដឹកនាំដោយសម្តេច ព្រះនរោត្តមសីហនុ គឺសម័យសង្គមរាស្ត្រនិយមនេះឯង បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ១៩២០ នៅតែអនុវត្តរហូតដល់ឈានចូលសម័យកម្ពុជាប្រជាធិបតេយ្យ អ្វីៗត្រូវផ្លាស់ប្តូរទាំងស្រុង ទ្រព្យសម្បត្តិឯកជនត្រូវបានហាមឃាត់ដាច់ខាត លើកលែងតែ ចាន ឆ្នាំង សំលៀកបំពាកនៅលើខ្លួនតែមួយសំរាប់ប៉ុណ្ណោះ ក្រៅពីនេះសុទ្ធសឹងជាទ្រព្យសម្បត្តិរបស់សមូហភាពទាំងអស់។ បន្ទាប់មកដល់សម័យរដ្ឋកម្ពុជា ច្បាប់ភូមិបាលក៏បានលេចរូបរាងឡើងដើម្បីកំណត់អំពីរបបកម្មសិទ្ធិ ។ ចំណែកកម្មសិទ្ធិឯកជនដោយឈរលើមូលដ្ឋាននៃក្រមរដ្ឋប្បវេណី ឆ្នាំ ១៩២០។ ក្រោយពីការប្រកាសរដ្ឋធម្មនុញ្ញថ្មី ឆ្នាំ ១៩៩៣ របបកម្មសិទ្ធិឯកជនត្រូវបានបញ្ជាក់សារជាថ្មីថា របបកម្មសិទ្ធិឯកជនមានតែចំពោះប្រជាជនដែលមានសញ្ជាតិខ្មែរតែ

ប៉ុណ្ណោះ។ ក្រោយពីការប្រកាសរដ្ឋធម្មនុញ្ញនេះ គេចាប់ផ្ដើមរៀបចំច្បាប់ភូមិបាល ឡើងវិញដោយធ្វើវិសោធនកម្មជាច្រើនលើក ច្រើនសារ ទើបអាចចេញច្បាប់ ភូមិបាល ឆ្នាំ ២០០១ ដើម្បីសម្របសម្រួលការគ្រប់គ្រងរបបកម្មសិទ្ធិ ហើយក្នុងនោះគេឃើញមានបញ្ញត្តិស្ដីពី លទ្ធកម្មដោយសន្តតិកម្មត្រង់មាត្រា ៧១ ដល់មាត្រា ៧៩ ដែលនិយាយពីសន្តតិកម្មមានបណ្ដាំ ឬអច្ច័យទាន ឬឥតបណ្ដាំចំពោះអចលនវត្ថុតែប៉ុណ្ណោះ។ ដោយសារតែការវិវត្តន៍នៃសង្គមពីមួយថ្ងៃ ទៅមួយថ្ងៃឥតឈប់ឥតឈររហូតមកដល់ឆ្នាំ ២០០៧ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចាប់បដិសន្ធិឡើងក្រោមការឧបត្ថម្ភគាំទ្រពីប្រទេសជប៉ុនដែលជាមិត្ត ដោយនៅក្នុងនោះបានកំណត់យ៉ាងច្បាស់លើកម្មសិទ្ធិឯកជន និងសន្តតិកម្ម។

តាមរយៈការសិក្សាកន្លងមក របបសន្តតិកម្មត្រូវបានបែងចែកជា ២ គោលការណ៍ធំៗ ក្នុងនោះរួមមាន ៖ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មានន័យថា សន្តតិជនត្រូវទទួលបន្តនូវមត៌កទាំងអស់ ដោយបូករួមនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជនផងដែរ មុននិងធ្វើការបែងចែក ឬធ្វើការសងបំណុលហើយអនុញ្ញាតឲ្យសន្តតិជន មានទទួលទាំងស្រុងផង ឬទទួលយកដោយកម្រិត ឬលះបង់សន្តតិកម្មតែម្ដង។ ចំណែកឯគោលការណ៍ជម្រះបញ្ជី គឺតម្រូវឲ្យជម្រះសិទ្ធិ និងកាតព្វកិច្ចជាមុនសិន ហើយសន្តតិជន គឺអាចតែទទួលបានមត៌កក្នុងករណី ដែលនៅសល់តែទ្រព្យសកម្មតែប៉ុណ្ណោះ ហើយករណីអស់តែទ្រព្យសកម្មច្រើនពេក នោះតម្រូវប្រកាសក្ស័យធន់នៃមត៌ក។ ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ បានកំណត់យកគោលការណ៍ ទទួលបន្តដោយស្វ័យប្រវត្តិ ព្រមទាំងបានកំនត់អំពីរបបនៃសន្តតិកម្មជាពីរប្រភេទផងដែរ ដោយក្នុងនោះមាន របបនៃសន្តតិកម្មតាមបណ្ដាំ និងរបបសន្តតិកម្មតាមបញ្ញត្តិច្បាប់។ សន្តតិកម្មតាមរយៈបណ្ដាំ គឺស្ដែងឡើងតាមរយៈឆន្ទៈរបស់មតកជនដែលធ្វើមុនពេលអស់ជីវិតទៅតាមទម្រង់ដែលច្បាប់បានកំណត់ ហើយសន្តតិជនដែលទទួលបន្តនោះ បានអនុវត្តទៅតាមឆន្ទៈនោះដោយខានមិនបាន។ ចំណែកឯសន្តតិកម្មដែលមតកជនមិនបានបង្ហាញឆន្ទៈអ្វីទាល់តែសោះមុនពេលអនិច្ចកម្ម សន្តតិកម្មនោះមានផ្លូវតែមួយគត់គឺ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលនៅជាធរមាន ដែលរបបនេះគេឲ្យឈ្មោះថាជាសន្តតិកម្មតាមច្បាប់។

ដោយសារប្រទេសកម្ពុជា ជាប្រទេសមួយដែលទើបតែងើបពីភ្លើងសង្គ្រាមស៊ីវិល និងរបបកម្ពុជាប្រជាធិបតេយ្យ ហេតុដូច្នេះហើយប្រជាពលរដ្ឋមួយចំនួនខ្វះចំណេះដឹង ជាពិសេសគឺចំណេះដឹងផ្នែកច្បាប់នេះតែម្ដង។ បើនិយាយពីសន្តតិកម្មវិញមានប្រជាពលរដ្ឋខ្លះបានយល់ដឹង ខ្លះទៀតយល់ដឹងពុំសូវច្បាស់ មានការយល់ច្រឡំខ្លះទៀតពុំបានយល់ដឹងសោះតែម្ដង រហូតដល់មានករណីជាច្រើនកើតឡើង ដូចជា នៅពេលសហព័ទ្ធណាម្ខាងស្លាប់ សហព័ទ្ធនៅរស់បានគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលស្លាប់តែម្នាក់ឯង ដោយមិនបែងចែកឲ្យកូនខ្លះទៀត ពេលសហព័ទ្ធណាម្នាក់ស្លាប់ បងប្អូន ឪពុកម្ដាយរបស់សហព័ទ្ធដែលស្លាប់នោះ ទៅទាមទារយកទ្រព្យ

សម្បត្តិពីសហាព័ទ្ធដែលនៅរស់ និងកូនរបស់មតកជន ហើយករណីខ្លះទៀត កូនៗបង្កើតឈ្លោះគ្នាជាមួយម្ដាយរឿងចែកទ្រព្យរបស់ឪពុកដែលស្លាប់ រហូតដល់មានការប្រើហិង្សាជាអាទិ៍។ ដោយឈរលើបញ្ហាទាំងអស់នេះទើបក្រុមយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវដើម្បីបញ្ចប់ការសិក្សាឆ្នាំទី ៤នេះ ដោយផ្ដោតទៅលើប្រធានបទស្ដីអំពី « សន្តតិកម្មតាមច្បាប់»។

តើការធ្វើសន្តតិកម្មតាមច្បាប់ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មានរូបភាព និងការអនុវត្តនីតិវិធីយ៉ាងដូចម្ដេច ដើម្បីជៀសវាងរងនូវការមោឃភាព និងសម្រួលដល់ការអនុវត្តដើម្បីអនុលោមទៅតាមប្បញ្ញត្តិច្បាប់ជាធរមាន។ ដើម្បីឆ្លើយតបទៅនឹង ចំណោទបញ្ហាខាងលើយើងខ្ញុំសូមធ្វើការបែងចែកប្រធានបទ « សន្តតិកម្មតាមច្បាប់» នេះជាបីជំពូកធំៗមាន៖

**ជំពូកទី ១ ទិដ្ឋភាពទូទៅនៃសន្តតិកម្មតាមច្បាប់**

**ជំពូកទី ២ ការបែងចែកមត៌កតាមច្បាប់**

**ជំពូកទី ៣ ការអនុវត្តសន្តតិកម្មតាមច្បាប់**

# ជំពូកទី ១
# ទិដ្ឋភាពទូទៅនៃសន្តិកម្ម

# ជំពូកទី ១

# ទិដ្ឋភាពទូទៅនៃសន្តតិកម្ម

សញ្ញាណសន្តតិកម្ម គឺជាសញ្ញាណមួយដែលកើតមានក្នុងសង្គមខ្មែរយើងជាយូរយារណាស់មកហើយ ដោយគ្រាន់តែសញ្ញាណនេះពុំត្រូវបានតាក់តែង ឬលើកឡើងនៅក្នុងបញ្ញត្តិច្បាប់។ ប៉ុន្តែ នៅក្នុងពេលដែលសង្គមកំពុងមានការរីកចម្រើន សញ្ញាណនៃសន្តតិកម្មក៏បានពង្រីកខ្លួនទៅតាមសង្គមដែរ។ យ៉ាងណាមិញ សន្តតិកម្មបានក្លាយជាចំណោទ និងបង្កើតនូវវិវាទជាច្រើននៅក្នុងសង្គមគ្រួសារនៃប្រជាជនខ្មែរយើង។ ដោយហេតុតែឃើញពីចំណោទជាច្រើនចំពោះបញ្ហាសន្តតិកម្មនេះ ក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ និងដែលត្រូវបានចាប់អនុវត្ត ដោយគោរពតាមច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានបញ្ញត្តិយ៉ាងលម្អិតអំពីសន្តតិកម្ម។

ដើម្បីជ្រួតជ្រាបពីទិដ្ឋភាពទូទៅនៃរបបសន្តតិកម្ម និងថាអ្វីទៅជាសន្តតិកម្មតាមច្បាប់ យើងខ្ញុំសូមបែងចែកជំពូកទី ១ នេះជាបីផ្នែក ដែលរួមមាន៖ ផ្នែកទី ១ សិក្សារបបនៃសន្តតិកម្មក្នុងប្រទេសកម្ពុជា ផ្នែកទី ២ លក្ខណៈសម្បត្តិនៃការទទួលបាន និងកាត់ផ្តាច់សិទ្ធិជាសន្តតិជន និងផ្នែកទី ៣ សិក្សាពី អានុភាពនៃសន្តតិកម្មតាមច្បាប់។

## ផ្នែកទី ១៖ របបនៃសន្តតិកម្មក្នុងប្រទេសកម្ពុជា

### កថាភាគទី ១៖ មូលដ្ឋាននៃប្រព័ន្ធសន្តតិកម្ម

#### ១.តើសន្តតិកម្មជាអ្វី?

សន្តតិកម្ម គឺជាការទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចដែលមានលើទ្រព្យសម្បត្តិ (មត៌ក) របស់បុគ្គលដែលបានទទួលមរណភាព ដោយបុគ្គលផ្សេង។

បុគ្គលដែលមានសិទ្ធិធ្វើសន្តតិកម្ម ហៅថាសន្តតិជន ហើយបុគ្គលដែលត្រូវបានគេធ្វើសន្តតិកម្ម (បុគ្គលដែលទទួលមរណភាព) ហៅថា មតកជន។

ទោះបីក្នុងករណីការប្រកាសពីការបាត់ខ្លួនក៏ដោយ ក៏ត្រូវបានចាត់ទុកថាជាមរណភាព ហេតុនេះ សន្តតិកម្ម ត្រូវបានចាប់ផ្តើម។[1]

#### ២.សិទ្ធិ និងកាតព្វកិច្ចលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្ម

អចលនវត្ថុ ប្រាក់ ប្រាក់សន្សំ ភាគហ៊ុន វត្ថុមានតម្លៃ សិទ្ធិលើបំណុល កាតព្វកិច្ចជាដើម។

[1] មាត្រា ៤៣ នៃក្រមរដ្ឋប្បវេណី

ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និងចេតិយ ឬចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ហើយមិនត្រូវចាត់ទុកជាមត៌កឡើយ។[2] ម្យ៉ាងទៀតនៅក្នុងរបបគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា បានបែងចែកប្រភេទនៃសន្តតិកម្មជាពីរប្រភេទ រួមមាន៖ សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មមានបណ្តាំ។

- សន្តតិកម្មតាមច្បាប់ គឺជាប្រព័ន្ធសន្តតិកម្មដែលធ្វើឡើងផ្អែកតាមបញ្ញត្តិនៃច្បាប់ជាធរមាន។
- ចំណែកឯសន្តតិកម្មមានបណ្តាំ គឺជាប្រព័ន្ធសន្តតិកម្មដែលធ្វើឡើងដោយផ្អែកតាមឆន្ទៈរបស់មតកជន។

## កថាភាគទី ២៖ សន្តតិកម្មតាមច្បាប់

### ១.ស្ថានភាពជាក់ស្តែងនៃសន្តតិកម្ម

ភាគច្រើនអាចដោះស្រាយដោយរលូន ដោយផ្អែកលើការពិភាក្សាគ្នា។

តែប្រសិនបើការពិភាក្សាមិនអាចឯកភាពគ្នា មានតែដោះស្រាយតាមផ្លូវតុលាការ ដោយយកបញ្ញត្តិនៃក្រមរដ្ឋប្បវេណីមកអនុវត្ត។

ទោះជាយ៉ាងណាក៏ដោយ នៅតែអាចមានការពិភាក្សាគ្នា ថាតើត្រូវដោះស្រាយដោយវិធីណា ក្នុងករណីដោះស្រាយតាមផ្លូវតុលាការ?

ទោះជាធ្វើការបែងចែកតាមផ្លូវតុលាការក៏ដោយ ចៅក្រម មិនត្រឹមតែធ្វើការបែងចែកឲ្យមានយុត្តិធម៌ប៉ុណ្ណោះទេ ថែមទាំងត្រូវគោរពទៅតាមទំនៀមទម្លាប់ និងឆន្ទៈរបស់ភាគីផងដែរ ដើម្បីអាចទទួលបានការដោះស្រាយមួយដ៏ល្អ។

### ២.វិធីបែងចែកមត៌ក

#### ក.តាមការពិភាក្សា

សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ខែ បានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម។

បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការឲ្យធ្វើការបែងចែកមត៌កនោះបាន។

តុលាការត្រូវធ្វើការពិចារណាទៅលើស្ថានភាពផ្សេងៗដើម្បីធ្វើការបែងចែក។ តុលាការត្រូវធ្វើការពិចារណានូវទំនៀមទម្លាប់នៅក្នុងតំបន់នោះ និងមតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន។

#### ខ.តាមផ្លូវតុលាការ (ករណីប្រទេសជប៉ុន)

---

[2] មាត្រា ១១៤៧ កថាខណ្ឌទី ២នៃក្រមរដ្ឋប្បវេណី

លំហូរនៃរឿងក្តីបែងចែកមត៌កនៅក្នុងប្រទេសជប៉ុន

❖ ពិនិត្យថាមានមតកសាសន៍ ឬទេ?

ក្នុងករណីមានមតកសាសន៍ ហើយពុំមានវិវាទពីខ្លឹមសារ និងអានុភាពទេនោះ ត្រូវបែងចែកតាមខ្លឹមសារនោះ។ប្រសិនបើមានវិវាទ ហើយមិនអាចដោះស្រាយដោយធ្វើការចរចារបាន ត្រូវធ្វើបណ្តឹងផ្សេង ដើម្បីដោះស្រាយ។

❖ តើនរណាខ្លះជាសន្តតិជន? ពិនិត្យទៅលើចំណែកមត៌កកំណត់ដោយច្បាប់របស់សន្តតិជនម្នាក់ៗ តើមានចំនួនប៉ុន្មាន?

❖ ពិនិត្យទៅលើមត៌ក តើមានអ្វីខ្លះ?

ក្នុងករណីមានវិវាទលើមត៌ក ហើយមិនអាចដោះស្រាយដោយការចរចារបាន ត្រូវធ្វើបណ្តឹង ដើម្បីដោះស្រាយ។

❖ វាយតម្លៃទៅលើមត៌ក ហើយពិនិត្យថាតើនៅសល់ចំនួនប៉ុន្មាន?

❖ ស្រាវជ្រាវថាតើមានភាគណាត្រូវកែសម្រួលដែរ ឬទេ (ការទទួលផលប្រយោជន៍ពិសេស ភាគនៃវិភាគទាន)

❖ គណនាពីចំនួនមត៌កជាក់ស្តែងដែលសន្តតិជនម្នាក់ៗនឹងត្រូវធ្វើសន្តតិកម្ម

❖ ស្រាវជ្រាវពីវិធីបែងចែក។

## ផ្នែកទី ២ លក្ខណៈសម្បត្តិនៃការទទួលបាន និងការផ្តាច់សិទ្ធិជាសន្តតិជន

### កថាភាគទី ១ លក្ខខណ្ឌនៃការទទួលបានសិទ្ធិជាសន្តតិជន

លក្ខខណ្ឌចម្បងបំផុត នៃការទទួលបានសិទ្ធិជាសន្តតិជននោះ គឺសន្តតិជនរូបនោះគប្បីតែជាបុគ្គលដែលនៅរស់រានមានជីវិតដល់ថ្ងៃចាប់ផ្តើមសន្តតិកម្ម[3] ទោះស្ថិតនៅក្នុងស្ថានភាពជាទារកក្នុងគភ៌ (១) ករណីសន្តតិជនស្ថិតនៅក្នុងស្ថានភាពជាទារកក្នុងគភ៌ ឬ (២) ជារូបវន្តបុគ្គល។

#### ១.ករណីសន្តតិជនស្ថិតនៅក្នុងស្ថានភាពជាទារកក្នុងគភ៌

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានបញ្ញត្តិឲ្យទារកក្នុងគភ៌របស់ម្តាយ ក៏អាចទទួលបានសិទ្ធិជាសន្តតិជនបានដែរ តែលក្ខខណ្ឌនោះគឺត្រូវតែរស់រានមានជីវិតក្រោយពេលកើត[4]។ ជាគោលការណ៍ ទារកក្នុងគភ៌នឹងត្រូវទទួលបានសន្តតិកម្មគិតចាប់ពីពេលបើកសន្តតិកម្ម ដោយមិនមែនចាប់

[3] មាត្រា ១១៤៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[4] មាត្រា ៩ កថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី

គិតពីថ្ងៃកើតនោះទេ[5]។ ការតាក់តែងច្បាប់បែបនេះ បានធ្វើឲ្យទារកក្នុងគភ៌ ក៏ទទួលបានផលប្រយោជន៍ដែលខ្លួនគួរតែទទួលបានផងដែរ ដោយក្នុងឋានៈជាសន្តតិជននៃសន្តតិកម្ម។

**២.ករណីសន្តតិជនជារូបវន្តបុគ្គល**

អនុលោមតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានបញ្ញត្តិអំពីបុគ្គលដែលក្លាយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនបាន លុះត្រាតែជារូបវន្តបុគ្គលដែលមានជីវិតក្រោយពីការកើត[6]។ រូបវន្តបុគ្គលក្នុងន័យនេះ សំដៅទៅលើមនុស្សពិតតាមធម្មជាតិដែលផ្ទុយទៅនឹងនីតិបុគ្គល[7]។ ជាការពិតណាស់សន្តតិជនដែលជារូបវន្តបុគ្គល មិនត្រឹមតែមានជីវិតរស់រាននោះទេ សន្តតិជនក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ និងលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច នៃសន្តតិកម្មដែរ ពោលគឺ មិនមែនជាបុគ្គលដែលច្បាប់បានហាមឃាត់[8]។ មួយវិញទៀត ដើម្បីធ្វើការគ្រប់គ្រង ចាត់ចែង ទៅលើចំណែកមត៌ក ដែលជាចំណែករបស់ខ្លួនបាន សន្តតិជននោះក៏តម្រូវឲ្យមានអាយុយ៉ាងហោចណាស់ ១៨ ឆ្នាំផងដែរ[9]។

ប៉ុន្តែក្នុងករណីដែលក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានលើកលែងដល់សន្តតិជន ដែលមិនទាន់គ្រប់អាយុ ១៨ឆ្នាំ ក៏អាចមានសិទ្ធិក្នុងការចាត់ចែងចំណែកមត៌កបានដែរ ដូចជា ករណីអត្តាធីនភាពដែលបានមកពីតុលាការ ដោយមូលហេតុអាចឯករាជ្យលើខ្លួនឯងបាន តាមរយៈការស្នើសុំរបស់សាមីខ្លួន ឬការយល់ឃើញថាមានផលប្រយោជន៍ចំពោះអនីតិជននោះ[10]។ លក្ខខណ្ឌផ្សេងទៀតក្នុងការទទួលអត្តាធីនភាពដោយពុំចាំបាច់មានការប្រកាសពីតុលាការគឺ អនីតិជនទាំងឡាយណាដែលបានរៀបអាពាហ៍ពិពាហ៍រួច ឬបានរៀបអាពាហ៍ពិពាហ៍ហើយតែលែងលះគ្នាវិញ ក៏អានុភាពនៃអត្តាធីនភាពនៅតែមានដដែល។

ក្នុងករណីដែលសន្តតិជនជាជនបរទេស ដែលមិនមានសញ្ជាតិខ្មែរ ហើយត្រូវទទួលបានចំណែកមត៌កតាមសន្តតិកម្ម ឬតាមអច្ច័យទានដែលជាដីធ្លី ហើយមិនមែនជាអគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ ឡើងទៅ គឺពុំអាចទទួលបានចំណែកសន្តតិកម្មនោះបានឡើយ។ ប្រសិនបើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ សុទ្ធតែពុំមានសញ្ជាតិខ្មែរនោះទេ ដីធ្លីដែលជាចំណែកមត៌ក ត្រូវបម្លែងក្លាយជាទ្រព្យរបស់នីតិបុគ្គល ធ្វើការគ្រប់គ្រងចាត់ចែងចំណែកមត៌កនោះដោយសន្តតិជនទាំងអស់នោះក្នុងនាមជានីតិបុគ្គលនោះ។ ក្នុងរយៈពេល ៣ (បី) ខែ នីតិបុគ្គលនោះត្រូវធ្វើការលក់ចំណែកមត៌កដែលជាដីធ្លីនោះ ដោយមានការយល់ព្រមទាំងអស់គ្នា ឬ

---

[5] មាត្រា ៩ កថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី

[6] មាត្រា ៦ នៃក្រមរដ្ឋប្បវេណី

[7] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រ ១៩

[8] មាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណី

[9] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណី

[10] មាត្រា ២១ នៃក្រមរដ្ឋប្បវេណី

ដោយមានកម្រិតពី សន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ។ រីឯថ្លៃដែលទទួលបានពីការលក់ចំណែកមត៌កក្នុងនាមជានីតិបុគ្គលនោះ នឹងក្លាយជាចំណែកមត៌ក ធ្វើការចែកឲ្យសន្តតិជនដែលមិនមានសញ្ជាតិខ្មែរទាំងអស់នោះ រីឯនីតិបុគ្គលខាងលើ នឹងត្រូវបញ្ចប់ភារកិច្ច ហើយត្រូវរំលាយចោល។

ផ្ទុយទៅវិញ ប្រសិនបើដីធ្លីដែលគ្រប់គ្រងចាត់ចែងដោយសន្តតិជន ដែលមិនមានសញ្ជាតិខ្មែរទាំងអស់ក្នុងនាមជានីតិបុគ្គល មិនបានលក់ដីធ្លី ក្នុងរយៈពេល ៣(បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ យល់ព្រមទាំងស្រុង ឬបានយល់ព្រមដោយមានកម្រិតក្នុងការចាត់ចែងលក់ ដូច្នេះសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ដែលមានសញ្ជាតិខ្មែរ នឹងទទួលបានចំណែកមត៌កដែលជាដីធ្លីនោះ រីឯនីតិបុគ្គលនោះត្រូវចាត់ទុកថាគ្មានអត្ថិភាព[11]។ក្នុងករណីសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ពុំមានសញ្ជាតិខ្មែរ ចំណែកមត៌កដែលជាដីធ្លីនោះ នឹងក្លាយជាកម្មសិទ្ធិរបស់រដ្ឋ[12]។

## កថាភាគទី ២៖ លក្ខខណ្ឌនៃការផ្តាច់សិទ្ធិជាសន្តតិជន

ក្រោយពីបានសិក្សាទៅលើលក្ខខណ្ឌក្នុងការទទួលបានសិទ្ធិជាសន្តតិជនរួចមក ឥឡូវយើងនឹងធ្វើការសិក្សាទៅលើលក្ខខណ្ឌដែលនាំឲ្យសន្តតិជនបាត់បង់សិទ្ធិជាសន្តតិជនម្តង ដែលអាចជា ករណីអភ័ព្វបុគ្គល(១) ឬក្នុងករណីបុគ្គលត្រូវបានផ្តាច់ពីមរតក (២) ដោយមតកជនកាលនៅរស់រានមានជីវិត។

### ១.ករណីអភ័ព្វបុគ្គល

ពាក្យ «អភ័ព្វបុគ្គល» សំដៅលើបុគ្គលទាំងឡាយណាដែលបាត់បង់សិទ្ធិជាសន្តតិជន និងមិនអាចទទួលបានចំណែកមត៌កអ្វីទាំងអស់ ដោយសារបុគ្គលទាំងនោះបានប្រព្រឹត្ត ឬស្ថិតនៅក្នុងស្ថានភាព និងលក្ខខណ្ឌដូចខាងក្រោម ដោយយោងតាមមាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ រួមមាន៖

ទី១ បុគ្គលដែលទទួលទោស ឬដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតលើមតកជន ឬលើជនដែលមានលំដាប់សន្តតិកម្មមុន ឬលំដាប់ស្មើគ្នាទោះបីជាដោយផ្ទាល់ក្តី ឬប្រយោលក្តី។

ទី ២ បុគ្គលដែលដឹងអំពីការសម្លាប់មតកជនតែមិនរាយការណ៍ ឬមិនបានប្តឹង។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះមិនអាចវិនិច្ឆ័យអំពើល្អ ឬអាក្រក់បាន ឬករណីអ្នកសម្លាប់ជាសហព័ទ្ធ ឬញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ។

ទី ៣ បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬកែប្រែមតកសាសន៍ ស្តីពីសន្តតិកម្មដោយការឆបោក ឬគំរាមកំហែង។

[11] មាត្រា ១១៥៥ នៃក្រមរដ្ឋប្បវេណី

[12] សៀវភៅ សន្តតិកម្ម រៀបរៀងដោយ មេធាវី«អ៊ីវ ប៉ូលី» ឆ្នាំ ២០១០,ទំព័រទ ៤

ទី ៥ បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬលាក់ទុកនូវលិខិតមតកសាសន៍ ស្តីពី សន្តតិកម្មរបស់មតកជន[13]។

**២.ករណីបុគ្គលត្រូវបានផ្តាច់ពីមត៌ក**

បុគ្គលមួយប្រភេទទៀតដែលនឹងមិនបានទទួលចំណែកមត៌កពីមតកជនដែរនោះ គឺបុគ្គលត្រូវបានផ្តាច់ពីមត៌ក ដោយសារតែមតកជនបានដាក់ពាក្យប្តឹងទៅតុលាការ ក្នុងការផ្តាច់មត៌កពីសន្តតិជនរូបនោះកុំឲ្យមានសិទ្ធិទទួលចំណែកមត៌កនៃសន្តតិកម្ម កាលពីមតកជននៅរស់។ ក្នុងន័យនេះ លក្ខខណ្ឌរបស់វាគឺ តម្រូវឲ្យមានការបង្ហាញឆន្ទៈពីមតកជនពេលនៅរស់ និងការត្រួតពិនិត្យភាពត្រឹមត្រូវ នៃពាក្យស្នើសុំរបស់មតកជននោះពីតុលាការ។ សកម្មភាពដែលច្បាប់បានចែងនោះមានដូចតទៅ៖

- ទី ១ បុគ្គលដែលបានធ្វើបាប ចំពោះមតកជន
- ទី ២ បុគ្គលដែលបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ។
- ទី ៣ បុគ្គលដែលអាចមើលថែទាំមតកជនពេលដែលមានជំងឺ ប៉ុន្តែបែរជាមិនមកថែទាំ។
- ទី ៤ បុគ្គលដែលបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត
- ទី ៥ បុគ្គលដែលបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ គួរឲ្យកត់សម្គាល់ជាអាទិ៍[14]។

[13] មាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណី

[14] មាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណី

## ផ្នែកទី ៣៖ អានុភាពនៃសន្តតិកម្មតាមច្បាប់

ក្នុងចំណុចនេះយើងនឹងបកស្រាយអំពីអានុភាពដែលជាផលគតិយុត្ត ដោយកើតអំពីសន្តតិកម្មតាមច្បាប់។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានចែងអំពីការចាប់ផ្តើមសន្តតិកម្ម ដោយកំណត់ឲ្យច្បាស់នូវ « ពេលវេលាបើកសន្តតិកម្មតាមច្បាប់» ដែលសិក្សាក្នុងកថាភាគទី ១ និង «ទីកន្លែងបើកសន្តតិកម្មតាមច្បាប់» ដែលសិក្សាក្នុងកថាភាគទី ២។ ការកំណត់ដូច្នេះ ដើម្បីផ្តល់លក្ខណៈងាយស្រួលក្នុងការកំណត់រកតុលាការដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទចំពោះរឿងក្តីសន្តតិកម្ម ក្នុងករណីវិវាទបានកើតមានឡើង។

### កថាភាគទី ១៖ ពេលវេលាបើកសន្តតិកម្មតាមច្បាប់

ជាគោលការណ៍ សន្តតិកម្មនឹងត្រូវបានចាប់ផ្តើមក្នុងករណី ដែលមតកជនត្រូវបានទទួល មរណភាព ចំណុច (១) ឬក្នុងករណីដែលមតកជននោះបានបាត់ខ្លួន ចំណុច (២)។

#### ១.ករណីបានទទួលមរណភាព

ជាទូទៅ លុះត្រាតែមតកជនបានទទួលមរណភាព ទើបច្បាប់អនុញ្ញាតឲ្យមានការបើកសន្តតិកម្មធ្វើការចែកចំណែកចំពោះទ្រព្យសម្បត្តិរបស់មតកជននោះ ផ្ទុយទៅវិញ ប្រសិនបើមិនមានមរណភាពរបស់មតកជនទេ គ្មានការបើកសន្តតិកម្មនោះទេ[15]។ ជាការពិតណាស់ មតកជនទទួលមរណភាពភ្លាម សន្តតិកម្មនឹងចាប់ផ្តើមភ្លាម ប៉ុន្តែមានតែសំបុត្រមរណភាពដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានទេ ទើបបញ្ជាក់អំពីការទទួលមរណភាពនៃមតកជនបាន។

#### ២.ករណីបាត់ខ្លួន

ក្រៅពីករណីទទួលមរណភាពនៃមតកជន ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក៏បានផ្តល់នូវលក្ខខណ្ឌមួយទៀតក្នុងការចាប់ផ្តើមសន្តតិកម្មដែរ នោះគឺការបាត់ខ្លួន។ ការបាត់ខ្លួនសំដៅទៅលើបុគ្គលមួយរូបដែលមិនមានវត្តមានក្នុងលំនៅដ្ឋានខ្លួន ព្រមទាំងមិនមានព័ត៌មានអ្វីទាំងអស់ពីបុគ្គលនេះ ឬក្នុងកាលៈទេសៈគ្រោះថ្នាក់បាត់បង់ជីវិតហើយពុំអាចដឹងបានថាបុគ្គលនោះស្លាប់ ឬរស់[16]។

ក្នុងករណីនេះ អ្នកដែលមានប្រយោជន៍ពាក់ព័ន្ធនៃបុគ្គលដែលបាត់ខ្លួន ដូចជាសហព័ទ្ធ អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល និងឪពុកម្តាយ អាចប្តឹងទៅតុលាការបាន ក្រោយរយៈពេល ៥(ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលបាត់ខ្លួនដោយគ្មានដំណឹងច្បាស់លាស់ថាស្លាប់ ឬ

[15] មាត្រា ១១៤៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី

[16] មាត្រា ៤១ នៃក្រមរដ្ឋប្បវេណី

ឬរស់នោះ[17]។ ប្រសិនបើបាត់ខ្លួនក្រោយរយៈពេល ១(មួយ) ឆ្នាំ ក្នុងសង្គ្រាម ឬនៅពេលនាវាលិច ឬជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗ ដែលគ្មានសង្ឃឹមថានៅរស់ អ្នកមានផលប្រយោជន៍ពាក់ព័ន្ធអាចប្ដឹងទៅតុលាការបាន[18]។

ក្នុងករណីដែលតុលាការបានចេញសេចក្ដីសម្រេចប្រកាសអំពីការបាត់ខ្លួន បុគ្គលនោះនឹងត្រូវចាត់ទុកថា បានទទួលមរណភាពដែលសេចក្ដីសម្រេចប្រកាសនោះ មានតម្លៃស្មើនឹងសំបុត្រមរណភាព[19]។ អាស្រ័យហេតុនេះ ថ្ងៃដែលចេញសេចក្ដីសម្រេចប្រកាសអំពីការបាត់ខ្លួន ត្រូវចាត់ទុកថ្ងៃចាប់ផ្ដើមសន្តតិកម្ម។

**កថាភាគទី ២៖ ទីកន្លែងបើកសន្តតិកម្មតាមច្បាប់**

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានកំណត់យកលំនៅឋានរបស់មតកជនដែលបានស្នាក់នៅចុងក្រោយមកធ្វើជាទីកន្លែងចាប់ផ្ដើមសន្តតិកម្មនៃមតកជន[20]។ ក្នុងករណីដែលបុគ្គលមានលំនៅឋានច្រើន ការកំណត់លំនៅឋានចុងក្រោយរបស់មតកជនគឺជា គន្លឹះក្នុងការបើកសន្តតិកម្មដើម្បីឲ្យដឹងថាតុលាការណាដែលមានសមត្ថកិច្ចក្នុងការដោះស្រាយរឿងក្ដីនោះ។ ដូច្នេះ មានតែកំណត់ហេតុនៃសៀវភៅស្នាក់នៅ ដែលបានកត់ត្រាដោយនគរបាលរដ្ឋបាលប៉ុណ្ណោះក្នុងការកំណត់ពីលំនៅឋានចុងក្រោយបាន។

[17] មាត្រា ៤១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី

[18] មាត្រា ៤១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី

[19] មាត្រា ៤៣ នៃក្រមរដ្ឋប្បវេណី

[20] មាត្រា ១១៤៦ នៃក្រមរដ្ឋប្បវេណី

# ជំពូកទី ២
# ការបែងចែកមត៌កតាមច្បាប់

# ជំពូកទី ២
# ការបែងចែកមត៌កតាមច្បាប់

បន្ទាប់ពីបានសិក្សាស្វែងយល់ពីចំណុច និងទិដ្ឋភាពទូទៅនៃសន្តតិកម្មតាមច្បាប់រួចហើយនោះនៅក្នុងជំពូកទី ២ យើងនឹងធ្វើការបកស្រាយអំពីការបែងចែកមត៌កនៃសន្តតិកម្មតាមច្បាប់បន្តទៀត ដែលក្នុងនោះយើងសូមបែងចែកជាពីរផ្នែកធំៗរួមមាន ផ្នែកទី ១ យើងសិក្សាពី លក្ខណៈសម្បត្តិនៃសន្តតិជន ផ្នែកទី ២ សិក្សាទៅលើ សិទ្ធិ និងកាតព្វកិច្ចលើបំណុលនៃសន្តតិកម្ម។

## ផ្នែកទី ១៖ លក្ខណៈសម្បត្តិនៃសន្តតិជន

ជាគោលការណ៍ សន្តតិកម្មអាចធ្វើឡើងបានតែចំពោះបុគ្គលដែលមានជីវិតរស់នៅ នៅពេលចាប់ផ្តើមសន្តតិកម្មតែប៉ុណ្ណោះ។ ដូច្នេះ ក្នុងករណីដែលមតកជន និងជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាពព្រមជាមួយគ្នា ឬក្នុងករណីដែលត្រូវបានសន្មតថា បានទទួលមរណភាពព្រមជាមួយគ្នា ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៥ ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនបំពេញល័ក្ខខ័ណ្ឌមានជីវិតរស់នៅ នៅពេលចាប់ផ្តើមសន្តតិកម្មទេ ដូច្នេះមិនអាចធ្វើសន្តតិកម្មបានឡើយ។ ជាក់ស្តែងតាមរយៈក្រមរដ្ឋប្បវេណី លំដាប់សន្តតិជនត្រូវបានកំណត់ជា ៣ លំដាប់ ដែលសុទ្ធតែជា កូនចៅ និងសាច់ញាតិរបស់មតកជន ដែលអាចជាបច្ឆាញាតិ បុព្វញាតិ និងសាខាញាតិ។ តួយ៉ាង សន្តតិជនលំដាប់ទី ១ គឺជាកូនរបស់មតកជន រួមទាំងកូនបង្កើត និងកូនស្មុំផងដែរ។ ចំណែកលំដាប់ទី ២ គឺសំដៅទៅលើបុព្វញាតិខ្សែផ្ទាល់របស់មតកជន ដែលមាន ឪពុកម្តាយ ឬជីដូនជីតាជាដើម។ រីឯ លំដាប់ទី ៣វិញ គឺបងប្អូនបង្កើត ឬរួមតែម្តាយ ឬរួមតែឪពុក។ នៅក្នុងផ្នែកនេះដែរ ក៏បានលើកឡើងនូវករណីចំនួនពីរ ដែលទាក់ទងទៅនឹងសន្តតិជនលំដាប់ទី ១ ដោយយើងធ្វើការបែងចែកជាពីរករណីក្នុងនោះរួមមាន៖ ករណីសន្តតិជនលំដាប់ទី ១ នៅរស់ និងមួយទៀត ករណីសន្តតិជនលំដាប់ទី ១ ស្លាប់។ ក្រៅពីសន្តតិជនតាមញាតិលោហិត និងសន្តតិកម្មជំនួសក៏មានសន្តតិជនពិសេសមួយទៀតដែល គឺក្រមរដ្ឋប្បវេណីបានចែងពី សន្តតិជនដែលជាសហព័ទ្ធ។

### កថាភាគទី ១៖ ជនដែលត្រូវទទួលបានសន្តតិកម្ម

#### ១.សន្តតិជនលំដាប់ទី ១

#### ក.ករណីសន្តតិជនលំដាប់ទី ១ នៅរស់

តាមរយៈ ស្មារតីនៃក្រមរដ្ឋប្បវេណី បានប្បញ្ញត្តិថា កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី ១ ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា[21]។ ពាក្យថា «កូនរបស់មតកជន»

[21] មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

មានន័យថា កូនដែលមានបុគ្គភាពត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់។ ដូច្នេះ ចំពោះកូនក្រៅអាពាហ៍ពិពាហ៍ ទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ប្រសិនបើទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់ទេ បុគ្គភាពតាមផ្លូវច្បាប់ក៏មិនអាចទទួលស្គាល់បានដែរ ដូច្នេះកូននោះមិនអាចក្លាយជាសន្តតិជនរបស់ឪពុកបានទេ។[22] ហើយចំពោះកូនដែលត្រូវបានសុំតាមរយៈការសុំកូនពេញលេញ ញាតិភាពតាមផ្លូវច្បាប់ជាមួយនឹងឪពុកម្តាយបង្កើត ត្រូវបានបញ្ចប់[23] ដូច្នេះកូននោះមិនអាចទទួលសន្តតិកម្មបានទេ ពោលគឺគេអាចទទួលសន្តតិកម្មតែពីឪពុកម្តាយចិញ្ចឹមប៉ុណ្ណោះ។ រីឯកូនសុំតាមសុំកូនធម្មតាវិញ អាចទទួលសន្តតិកម្មពីឪពុកម្តាយបង្កើតផង និងពីឪពុកម្តាយចិញ្ចឹមផង[24]។ ជាធម្មតា សំបុត្រកំណើត គឺជាភស្តុតាងមួយដ៏សំខាន់ក្នុងការបញ្ជាក់ពីទំនាក់ទំនងគតិយុត្តិរវាងកូន និង ឪពុកម្តាយ។ វាជាករណីកិច្ចរបស់ឪពុកម្តាយ ដែលត្រូវសុំចុះសំបុត្រកំណើតកូន ទោះបីជាឪពុកម្តាយនោះបានរៀបអាពាហ៍ ឬក៏មិនបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ មន្ត្រីអត្រានុកូលដ្ឋាន ដែលជាមេឃុំ ឬចៅសង្កាត់ស្ថិតនៅក្នុងដែនដីឃុំ ឬសង្កាត់ដែលខ្លួនបានគ្រប់គ្រងគឺមានតួនាទីក្នុងការចុះអត្រានុកូលដ្ឋាន។ ឪពុក ឬម្តាយរបស់កូនត្រូវចុះសំបុត្រកំណើត នៅសាលាឃុំ ឬសង្កាត់នៃលំនៅឋានរបស់ឪពុកម្តាយក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃគិតពីថ្ងៃដែលកូននោះបានកើត[25]។ ក្នុងករណីដែលម្តាយឪពុកមិនអាចសុំចុះបានទេនោះ ញាតិដែលជានីតិជនដែលរស់នៅជាមួយឪពុកម្តាយនៃកូនត្រូវសុំចុះសំបុត្រកំណើតរបស់កូននោះឲ្យបានឆាប់រហ័ស។ ប្រសិនបើ ម្តាយឪពុកបានធ្វេសប្រហែសនឹងករណីកិច្ចសុំចុះសំបុត្រកំណើតរបស់កូននោះ តាមពេលវេលាដែលច្បាប់បានកំណត់ខាងលើ នឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១០.០០០ (មួយម៉ឺន)រៀល[26]។

**ខ.ករណីសន្តតិជនលំដាប់ទី ១ ស្លាប់**

ដូចបានរៀបរាប់ខាងលើរួចមកហើយ ជាគោលការណ៍កូនរបស់មតកជន គឺជាសន្តតិជនលំដាប់ ១។ ផ្ទុយទៅវិញនៅពេលដែលកូនមតកជនបានទទួលមរណភាព នៅមុនពេល ឬព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬបាត់បង់សិទ្ធិសន្តតិកម្ម ដោយមូលហេតុអភ័ព្វបុគ្គលនៃសន្តតិកម្ម (មាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា) ឬដោយការផ្តាច់មត៌ក កូនរបស់សន្តតិជននោះនឹងក្លាយជាសន្តតិជនជំនួស[27]។ ក្នុងករណីដែលកូនរបស់មតកជនទទួលមរណភាពក្រោយពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនដែល

[22] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦

[23] មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណី

[24] មាត្រា ១០២៦ នៃក្រមរដ្ឋប្បវេណី

[25] មាត្រា ៩៨៥ នៃក្រមរដ្ឋប្បវេណី

[26] មាត្រា ៩៨៥ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី

[27] មាត្រា ១១៥៨ នៃក្រមរដ្ឋប្បវេណី

ស្លាប់នោះទទួលសន្តតិកម្មរបស់មតកជន ហើយកូនរបស់សន្តតិជនដែលស្លាប់នោះ នឹងទទួលសន្តតិកម្មបន្តទៀត ដោយសារតែមរណភាពរបស់សន្តតិជនដែលស្លាប់នោះ[28]។ ចំពោះករណីសុំកូនវិញ នៅពេលដែលមតកជនបានសុំកូនដែលមានកូនរួចហើយតាមរយៈសុំកូនធម្មតានោះ កូនរបស់កូនសុំនោះមិនអាចក្លាយជាសន្តតិជនជំនួសបានឡើយ ដោយសារកូននោះមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ប៉ុន្តែលើកលែងក្នុងករណីដែលកូនរបស់កូនសុំធម្មតានោះ កើតក្រោយពេលដែលបានសុំកូន កូននោះអាចក្លាយជាសន្តតិជនជំនួសបាន ដោយហេតុថាកូនដែលកើតនោះជាបច្ឆាញាតិផ្ទាល់របស់មតកជន និងមិនអាចត្រូវបានហាមឃាត់ដោយវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

ការទទួលបន្តនូវសន្តតិកម្មជំនួស ដោយមូលហេតុដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណី គឺដោយមូលហេតុអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬដោយការផ្តាច់មត៌ក នាំឲ្យកូនរបស់សន្តតិជនក្លាយជាសន្តតិជនជំនួសបន្តទៀត ហើយប្រសិនបើកូន និងចៅរបស់មតកជនបានទទួលមរណភាពទៀតនោះ ចៅទួតនឹងទទួលមរតកបន្តទៀត ដែលជាការទទួលមត៌កជាបន្តបន្ទាប់គ្នា។ គេអនុវត្តបែបនេះជាបន្តបន្ទាប់ផងដែរ ប្រសិនបើចៅទួតមានមូលហេតុដូចគ្នានេះ។ ការអនុវត្តសន្តតិកម្មជំនួសបន្តបន្ទាប់បែបនេះ អាចអនុវត្តបានចំពោះតែសន្តតិជនដែលជាកូនរបស់មតកជន ពោលគឺជាបច្ឆាញាតិផ្ទាល់របស់មតកជនតែប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងករណីដែលបងប្អូនបង្កើត ដែលជាសន្តតិជនលំដាប់ទី ៣ ជាអ្នកទទួលបានមត៌កវិញ ច្បាប់ទទួលស្គាល់សន្តតិកម្មជំនួសត្រឹមតែមួយតំណប៉ុណ្ណោះ ពោលគឺក្មួយរបស់មតកជនអាចក្លាយជាសន្តតិជនជំនួសបាន[29]។ ប៉ុន្តែពុំមានករណីសន្តតិកម្មជំនួសដែលធ្វើឡើងដោយកូនរបស់ក្មួយប្រុស ឬក្មួយស្រីឡើយ។ ចំណែកមត៌កនៃសន្តតិជន ត្រូវបានគេអនុវត្តដូចគ្នាទៅនឹងចំណែកមត៌ក ដែលបុព្វញាតិផ្ទាល់ទទួលបាន ដោយត្រូវបានចំណែកស្មើគ្នា លើកលែងតែក្នុងករណីដែលមានបច្ឆាញាតិផ្ទាល់ច្រើននាក់ ត្រូវបែងចែកស្មើៗគ្នារវាងបច្ឆាញាតិទាំងឡាយដែលជាសន្តតិជនជំនួស ដោយធៀបទៅនឹងចំណែកមត៌ករបស់បុព្វញាតិរបស់ពួកគេទទួលបាន។

ឧទាហរណ៍៖ លោក ក ដែលជាមតកជន មានកូនបីនាក់ ខ គ និង ឃ។ ក្រោយពេលស្លាប់ លោក ក បានបន្សល់ទុកនៅទ្រព្យសម្បត្តិ ៦០០០ ដុល្លារ។ មុនពេលចាប់ផ្តើមសន្តតិកម្ម លោក ខ ដែលជាកូន បានទទួលមរណភាព ដោយបន្សល់ទុកនៅកូនចំនួន ២ នាក់ដែលជាចៅរបស់លោក ក។ ហេតុដូច្នេះ តាមសម្មតិកម្មខាងលើ ទ្រព្យសម្បត្តិដែលជាសន្តតិកម្ម ត្រូវបានបែងចែកជាបីចំណែកស្មើៗគ្នា ដោយម្នាក់ៗត្រូវទទួលបាន ២០០០ ដុល្លារ។ មួយវិញទៀតដោយសារ លោក ខ ទទួលមរណភាពមុនសន្តតិកម្មដូច្នេះ កូនរបស់លោក ខ នឹងត្រូវក្លាយ

[28] ទំព័រទី ១៥ សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ភាគ ៦: គន្លឹះទី ៨ និង៩ ក្រសួងយុត្តិធម៌

[29] មាត្រា ១១៦០ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី

ជាសន្តតិជនជំនួសឪពុកដើម្បីទទួលចំណែករបស់ឪពុកទៅតាមច្បាប់កំណត់។ ដោយសារ លោក ខ មានកូន ពីរនាក់ ដូច្នេះ ចំណែកមត៌ករបស់គាត់ ត្រូវចែកឲ្យកូនស្មើៗគ្នា ដោយក្នុងនោះ ចំណែករបស់គាត់គឺ ២០០០ ដុល្លារ ហើយគាត់បន្សល់ទុកនូវកូន ២ នាក់ ដូច្នេះកូនរបស់គាត់ម្នាក់ៗ ត្រូវទទួលបាន ១០០០ ដុល្លារ។

**២.សន្តតិជនលំដាប់ទី ២**

ជាធម្មតា នៅពេលដែលអវត្តមាន ឬមិនមានបច្ឆាញាតិផ្ទាល់ ដែលនឹងត្រូវក្លាយជាសន្តតិជននោះទេ ច្បាប់បានអនុញ្ញាតឲ្យ បុព្វញាតិផ្ទាល់របស់មតកជននឹងក្លាយជាសន្តតិជន នៅលំដាប់ទី ២។ កម្មវត្ថុចម្បងដែលច្បាប់អនុញ្ញាត ឲ្យធ្វើបែបនេះពីព្រោះ បុព្វញាតិផ្ទាល់ដែលជា ឪពុកម្តាយ ជីដូនជីតា របស់មតកជនជាសន្តតិជនលំដាប់ទី ២ ដោយគេគិតថាអ្នកទាំងនោះគឺជាអ្នកដែលទទួលបានការគោរពពីមតកជន និងជាអ្នកបានមើលថែទាំ ចិញ្ចឹមបីបាច់មតកជន ដែលជាកូន ឬចៅ។ ជាក់ស្តែង ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ផងដែរថា អ្នកដែលជាបុព្វញាតិ ដែលមានលំដាប់ថ្នាក់ជិតជាងគេ[30]ទៅនឹងមតកជនជាអ្នកដែលមានអាទិភាពទទួលបានចំណែកមត៌ក។ នោះឪពុកម្តាយរបស់មតកជននឹងក្លាយជាសន្តតិជនលំដាប់ទី ២ មុនជីដូនជីតា។ តែប្រសិនបើឪពុករបស់មតកជនបានទទួលមរណភាព ហើយទោះបីជាជីដូនជីតាខាងឪពុកនោះនៅរស់ក៏ដោយ ប្រសិនបើម្តាយរបស់មតកជននោះនៅរស់ ម្តាយនោះជាអ្នកជិតជាងគេក្នុងថ្នាក់ញាតិ ដូច្នេះ ម្តាយ គឺជាសន្តតិជនលំដាប់ទីពីរតែម្នាក់ឯង។ ជីដូនជីតាខាងឪពុកមិនទទួលសន្តតិកម្មជំនួសឡើយ។ ក្នុងករណីដូចគ្នានេះ ប្រសិនបើម្តាយរបស់មតកជនក៏បានទទួលមរណភាពដែរ នោះជីដូនជីតាខាងម្តាយ និងជីដូនជីតាខាងឪពុក ត្រូវទទួលសហសន្តតិកម្ម[31]។ ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា[32]។

**៣.សន្តតិជនលំដាប់ទី ៣**

ប្រសិនបើមតកជន មិនមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះត្រូវក្លាយជាសន្តតិជន លំដាប់ទី ៣[33]។ ទោះបីជាបងប្អូនបង្កើតរបស់មតកជនមានប៉ុន្មាននាក់ក៏ដោយ ក៏បងប្អូនបង្កើតម្នាក់ៗត្រូវទទួលបានចំណែកមត៌កស្មើៗគ្នាជានិច្ច។ ប៉ុន្តែចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាងដូចគ្នាទៅនឹងមតកជន អាចទទួលបានតែ ១ភាគ ២(មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និងម្តាយទាំងសងខាងដូចគ្នា។ ហើយប្រសិនបើ បងប្អូន

[30] មាត្រា ១១៦១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី
[31] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី ៦
[32] មាត្រា ១១៥៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី
[33] មាត្រា ១១៦០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី

បង្កើតបានទទួលមរណភាពហើយ នោះសន្តតិកម្មជំនួសនឹងត្រូវបានទទួលស្គាល់ត្រឹមតែមួយតំណប៉ុណ្ណោះ មានន័យថា ជាកូនរបស់បងប្អូនបង្កើតនោះ ដែលមានដូចជា ក្មួយក្រុស ស្រីរបស់មតកជន ត្រូវធ្វើសន្តតិកម្មជំនួស[34]។

ឧទាហរណ៍៖ លោក ក ជាមតកជនបានទទួលមរណភាពដោយគ្មានកូន ហើយឪពុកម្ដាយរបស់គាត់បានទទួលមរណភាពដូចគ្នា។ លោក ក មានបងប្អូនបង្កើត ចំនួន ២នាក់ គឺ ខ និង គ។ ឪពុករបស់លោក ក ពេលនៅរស់មានកូនផ្សេងម្នាក់ទៀតឈ្មោះ ឃ ដែលមានម្ដាយខុសគ្នាពីលោក ក។ ដូចនេះ សន្តតិជនរបស់លោក ក គឺមាន ខ គ និង ឃ ហើយចំណែកមត៌ករបស់ ឃ គឺស្មើនឹងពាក់កណ្ដាលនៃចំណែកមត៌ករបស់ ខ និង គ ដែលជាបងប្អូនបង្កើតមានឪពុកម្ដាយរួមគ្នា។ នោះ ខ និង គ ទទួលបានចំណែកមត៌កម្នាក់ ២ ភាគ ៥ រីឯ ឃ ទទួលបានតែ ១ ភាគ ៥ ប៉ុណ្ណោះ។

**៤.សន្តតិកម្មរបស់សហព័ទ្ធ**

ករណីដែលមតកជនមានសហព័ទ្ធ នោះសហព័ទ្ធនោះក៏អាចទទួលបាននូវចំណែកមត៌ករបស់មតកជនបានដែរ ទោះបីជាសហព័ទ្ធមិនមាននូវទំនាក់ទំនងញាតិលោហិតជាមួយមតកជនដូចនឹងសន្តតិជនដទៃក៏ដោយ ដែលករណីនេះក្រមរដ្ឋប្បវេណីបានទទួលស្គាល់សហព័ទ្ធនោះថាសន្តតិជនជានិច្ច[35]។ ទោះបីជាមាននូវសន្តតិជន ឬគ្មានសន្តតិជនផ្សេងៗទៀតក៏ដោយ ក៏សហព័ទ្ធត្រូវបានច្បាប់ទទួលស្គាល់សិទ្ធិសន្តតិកម្ម ហើយជាពិសេសត្រូវទទួលបាននូវមត៌កដែលជាចំណែកនៃទ្រព្យដោយឡែក និងទ្រព្យរួមរបស់មតកជន។ ពាក្យថា «ជានិច្ច» នៅក្នុងន័យនេះ សំដៅទៅលើការគ្មានការពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេងព្រមទាំងលំដាប់សន្តតិកម្មឡើយ។ ជានិច្ចកាល សន្តតិជនជានិច្ច ត្រូវទទួលបាននូវចំណែកមត៌កជាមួយនឹងសន្តតិជនផ្សេងៗទៀតគ្រប់លំដាប់ទាំងអស់ ដោយមិនគិតថាជាបុព្វញាតិ បច្ឆាញាតិ ឬក៏ជាបងប្អូនបង្កើតឡើយ។ ប្រសិនបើមតកជនណាម្នាក់ គ្មានសន្តតិជនពីលំដាប់ទី ១ ដល់លំដាប់ទី ៣ នោះទេ សហព័ទ្ធនឹងទទួលសន្តតិកម្មតែម្នាក់ឯង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧[36]។

## កថាភាគទី ២៖ ការសម្រួលចំណែកមត៌កនៃសន្តតិជន

**១.ចំណែកសន្តតិកម្មតាមច្បាប់**

ករណីសន្តតិជន ជាកូន ចំណែកសន្តតិកម្មរបស់កូននីមួយៗគឺស្មើភាពគ្នា។

[34] មាត្រា ១១៦០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[35] មាត្រា ១១៦១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[36] ទំព័រទី ២១ សេចក្ដីកំណត់ក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី ៨ និង៩ ក្រសួងយុត្តិធម៌

ករណីមតកជនពុំមានបច្ឆាញាតិផ្ទាល់ ច្បាប់អនុញ្ញាតឲ្យបុព្វញាតិផ្ទាល់ (ឪពុក-ម្តាយ ជាអាទិ៍) របស់មតកជននឹងទទួលបានចំណែកមត៌កស្មើៗគ្នា។

ករណីមតកជន ពុំមានបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់ បើបងប្អូនបង្កើតរបស់មតកជនមានចំនួនច្រើននាក់នឹងទទួលបានចំណែកមត៌កស្មើៗគ្នា។ ប៉ុន្តែចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាង នឹងទទួលបានចំណែកមត៌កតែ ១/២ នៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក-ម្តាយទាំងសងខាងដូចគ្នា។

ឧទាហរណ៍ ៖ បុរស «A» បានស្លាប់ដោយបន្សល់ទុកនូវមត៌កចំនួន ១.៥០០ ។ បុរស «A» គ្មានប្រពន្ធ គ្មាន កូន និងបុព្វញាតិនោះទេ។ បុរស «A» មានបងប្អូនបង្កើតចំនួន ០៣ (បី) នាក់ ឈ្មោះ «O» «P» និង«Q»។ ប៉ុន្តែ «Q»និង «A» គឺជាបងប្អូនរួមឪពុក និងម្តាយទីទៃ។

ករណីនេះ ចំណែកមត៌ករបស់ «O» «P» និង «Q» ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

«O» បានពីរចំណែកនៃ «Q» រីឯ «P» បានពីរចំណែកនៃ «Q» ហើយ «Q» បានមួយចំណែក ហេតុនេះ ចំណែកមត៌តរបស់ «O» គឺ ៦០០ ចំណែកមត៌ករបស់ «P» គឺ ៦០០ និង «O» គឺ ៣០០។

ប្រសិនបើសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងទៀតក្លាយជាសន្តតិជន ចំណែកមត៌កត្រូវធ្វើការបែងចែកដូចខាងក្រោម៖

-បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់ ជាសន្តតិជន នាំឲ្យទទួលចំណែកមត៌កស្មើៗគ្នា។

-បើសហព័ទ្ធ និងឪពុក-ម្តាយរបស់មតកជនជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ គឺ ១/៣ រីឯឪពុក-ម្តាយ គឺ ២/៣ ។ ប៉ុន្តែ បើឪពុក ឬម្តាយរបស់មតកជននៅរស់តែម្នាក់ ឪពុក ឬម្តាយជាមួយនឹងសហព័ទ្ធនឹងទទួលបានចំណែកមត៌កស្មើៗគ្នា។

-បើសហព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុក-ម្តាយ ឬបងប្អូនបង្កើត ឬអ្នកជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធគឺ ១/២ រីឯបុគ្គលទាំងនោះគឺ ១/២ [37]។

**២.ផលប្រយោជន៍ពិសេស**

ការសម្រួលចំណែកមត៌ក គឺជាវិធានធ្វើឲ្យមានសមភាពជាក់ស្តែងនៅក្នុងចំណោម សន្តតិជនដែលបានទទួលនូវផលប្រយោជន៍ពិសេស ឬប្រទានកម្ម នៅមុនពេលម្ចាស់ទ្រព្យបានស្លាប់។ ផលប្រយោជន៍ពិសេសជាផលប្រយោជន៍ដែលបុគ្គលណាម្នាក់ ឬច្រើននាក់បានទទួលជាប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជន។ អច្ច័យទាន

[37] មាត្រា ១១៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដែលត្រូវបានផ្តល់ទៅឲ្យសន្តតិជន ក៏ត្រូវចាត់ទុកជាផលប្រយោជន៍ពិសេសផងដែរ ប៉ុន្តែពុំត្រូវរាប់បញ្ចូលក្នុងការគណនានោះទេ ព្រោះអច្ច័យទានពុំទាន់ត្រូវបានបែងចែកឲ្យទៅសន្តតិជនឡើយ នៅពេលចាប់ផ្តើមសន្តតិកម្ម។

ការទទួលផលប្រយោជន៍ពិសេស គឺជាប្រព័ន្ធដែលធ្វើឲ្យមានសមភាពរវាងសន្តតិជន នៅពេលធ្វើសន្តតិកម្មដោយពិចារណា ចំពោះករណីដែលសន្តតិជនតែម្នាក់បានទទួលប្រទានកម្មជា វត្ថុ ឬប្រាក់ពីមតកជនក្នុងចំណោមសន្តតិជនច្រើននាក់។ បើយើងក្រឡេកទៅមើល ពីនិយមន័យដែលពាក់ព័ន្ធនឹងផលប្រយោជន៍ពិសេសដែលមានចែងក្នុងមាត្រា ១១៦៣ បានកំណត់ថា ផលប្រយោជន៍ពិសេសបានស្តែងឡើងតាមរយៈ៖

- ប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ និង
- អច្ច័យទាន ដែលប្រគល់ឲ្យទៅសន្តតិជន។

នៅពេលដែលយើងស្គាល់អំពីផលប្រយោជន៍ពិសេសបានច្បាស់លាស់ហើយ យើងនឹងធ្វើការស្វែងយល់ពីអ្នកដែលទទួលបានផលប្រយោជន៍ពិសេស ចំពោះមរតករបស់ខ្លួនដោយខ្លួនបានទទួលផលប្រយោជន៍ពិសេស និងជាសហសន្តតិជន ដែលមានចំណែកចំពោះមត៌ក ដើម្បីដឹងច្បាស់ ថាតើ ចំណែកមរតករបស់អ្នកទទួលផលប្រយោជន៍ពិសេសមានចំនួនប៉ុន្មាន នៅពេលសម្រួលចំណែករបស់ខ្លួន តាមច្បាប់។ ដោយឡែក នៅពេលមានភាគនៃវិភាគទាន ជាស្ថានភាពនៃការចំណាយទ្រព្យសម្បត្តិរបស់សហសន្តតិជនណាម្នាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់ ដើម្បីបង្កើនទ្រព្យរបស់មតកជន ឬចំណាយសម្រាប់ជីវភាពរបស់មតកជន ឬចំណាយដើម្បីមើលថែទាំមតកជន វិធាននៃការសម្រួលចំណែកមត៌កត្រូវកើតឡើង ដើម្បីឲ្យមានសមភាពជាក់ស្តែងសម្រាប់សន្តតិជនដែលបានចំណាយទ្រព្យផ្ទាល់ខ្លួន។

**កម្មវត្ថុនៃការសម្រួលចំណែកមត៌ក**

ជាគោលការណ៍ សន្តតិជនត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា ប៉ុន្តែប្រសិនបើ មានជនដែលទទួលផលប្រយោជន៍ពិសេស យើងមិនអាចយកចំណែកមត៌កជាក់ស្តែង ទៅចែកឲ្យសន្តតិជនទាំងអស់ ដោយមិនសម្រួលចំណែកមត៌កនោះទេ ព្រោះបំពានខ្លឹមសារនៃការទទួលបានចំណែកមត៌កជាក់ស្តែង ដូចនេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីចំណែកមត៌កនៃជនដែលទទួលផលប្រយោជន៍ពិសេស តាមវិធីនៃការសម្រួលចំណែក។

β **វិធីសម្រួលចំណែកមត៌ក**

នៅក្នុងចំណោមសហសន្តតិជនទាំងអស់ មានសន្តតិជនណាម្នាក់ ឬច្រើននាក់បានទទួលនូវប្រទានកម្ម ឬអច្ច័យទានពីមតកជន តម្លៃសរុបនៃមរតកត្រូវយកទ្រព្យរបស់មតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម

បូកបញ្ចូលតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកជាមរតកហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីការដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទានចេញពីចំណែកមរតក គឺជាចំណែកមរតករបស់បុគ្គលនោះ[38]។

**រូបមន្តៈ** មត៌កសរុប= មត៌កពេលចាប់ផ្ដើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស

**ចំណែកមត៌កនៃអ្នកមានផលប្រយោជន៍ពិសេស** = $\frac{\text{មត៌កសរុប}}{\text{ចំនួនសន្តតិជន}}$ – ផលប្រយោជន៍ពិសេស

ឧទាហរណ៍ទី១ ក្នុងករណីដែលសន្តតិជន A B និង C ធ្វើសន្តតិកម្មមត៌ក ១០០០ ដុល្លារដោយបែងចែកស្មើៗគ្នា ហើយ A ទទួលបានផលប្រយោជន៍ពិសេសចំនួន ២០០ ដុល្លារពីមតកជនពេលនៅរស់ ដូច្នេះចំណែកមត៌ករបស់ A ត្រូវគណនាដូចខាងក្រោម៖

(១០០០ ដុល្លារ (មត៌ក) + ២០០ ដុល្លារ (ផលប្រយោជន៍ពិសេស))÷៣នាក់ - ២០០ដុល្លារ (ផលប្រយោជន៍ពិសេស) = ២០០ ដុល្លារ។

ឧទាហរណ៍ទី២ ៖ Ă = B មត៌ក US$ 3000




C ទទួលបានផលប្រយោជន៍ពិសេស US$ 3000

ចម្លើយ៖ $c = \frac{3,000+3,000}{4}$=1500-3000=-1500 (លើសចំណែកមត៌ក)

B = D = E = $\frac{3000+3000}{4} = 1500$

ប៉ុន្តែមត៌កជាក់ស្តែងមានតែ ៣០០០ តែប៉ុណ្ណោះ មិនគ្រប់គ្រាន់សម្រាប់សន្តតិជន ០៣ នាក់ដែលត្រូវទទួលចំណែកដល់ ១៥០០ ម្នាក់ៗស្មើនឹង ៤៥០០ នោះទេ ហេតុនេះ ត្រូវសមាមាត្រ ដោយម្នាក់ៗទទួលបាន ១០០០ ហើយ C មិនទទួលបានចំណែកមត៌កនោះទេ និងយោងតាមមាត្រា ១១៦៣ កថាខណ្ឌទី ២ និង ១១៦៥ នៃក្រមរដ្ឋប្បវេណី C ពុំចាំបាច់បង្វិលមកវិញ។

ហេតុនេះជាលទ្ធផលចុងក្រោយ ចំណែកមត៌ករបស់សន្តតិជនម្នាក់ៗគឺ ៖

B = 1000, D= 1000, E= 1000 & C=0

ការផ្តល់ផលប្រយោជន៍ពិសេស អាចវាយតម្លៃថាជា «ការប្រគល់មត៌កឲ្យជាមុន»។ នៅប្រទេសជប៉ុន ការទទួលផលប្រយោជន៍ពិសេសត្រូវយកមកអនុវត្តក្នុងករណីដូចខាងក្រោមនេះ។ប៉ុន្តែ ដោយផ្អែកតាមស្ថាន

[38] មាត្រា ១១៦៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ភាពជីវភាពរបស់សន្តតិជន ឬចំនួនទឹកប្រាក់ មានករណីខ្លះមិនមែនជាផលប្រយោជន៍ពិសេសទេ ហើយត្រូវអនុវត្តជាអាហារកាតព្វកិច្ច ឬការចំណាយប្រាក់ធម្មតាទៅវិញ។

-ប្រាក់ដែលចំណាយសម្រាប់ការរៀបអាពាហ៍ពិពាហ៍របស់កូន ឬប្រាក់សម្រាប់ធ្វើទុនប្រកបរបរ។

-ប្រទានកម្មអចលនវត្ថុ

-ប្រទានកម្មចំនួនទឹកប្រាក់សមរម្យ

-ថ្លៃសិក្សាចំពោះការបណ្តុះបណ្តាលនៅសាកលវិទ្យាល័យជាដើម (មានករណីដែលសន្តតិជនបានចំណាយដោយខ្លួនឯងជាដើម នឹងមិនត្រូវចាត់ទុកថាជាការទទួលផលប្រយោជន៍ពិសេសទេ)។

**៣.ករណីមានប្រទានកម្ម**

តម្លៃនៃប្រទានកម្មដែលជាមូលដ្ឋាននៃការគណនា ក្នុងករណីអ្នកទទួលផលប្រយោជន៍ពិសេស បានចាត់ចែង ឬបាត់បង់ទ្រព្យដែលទទួលបានដោយប្រទានកម្ម មុនពេលចាប់ផ្តើមសន្តតិកម្ម ជាអាទិ៍ ត្រូវយកតម្លៃនៅពេលចាត់ចែង ឬបាត់បង់ទ្រព្យនោះ។ មួយវិញទៀត ប្រសិនបើកម្មវត្ថុនៃប្រទានកម្ម ជារូបិយវត្ថុអាចមានការផ្លាស់ប្តូរ ប៉ុន្តែមិនមែនជាបញ្ហាសន្តតិកម្មនោះទេ គឺជាបញ្ហានៃការបកស្រាយ ថាតើត្រូវកំណត់តម្លៃនោះនៅពេលចាប់ផ្តើមសន្តតិកម្ម ឬនៅពេលចាត់ចែង ជាអាទិ៍។ ចំណុចនេះ នៅប្រទេសជប៉ុន បកស្រាយថា កំណត់យកតម្លៃនៅពេលចាប់ផ្តើមសន្តតិកម្ម (សាលដីកាតុលាការកំពូលជប៉ុន ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៦)។

ការពិចារណារបស់តុលាការកំពូលជប៉ុនចំពោះបញ្ហានេះ គឺទី ១ ទ្រព្យទាំងឡាយត្រូវសន្មតថាមិនមានការប្រែប្រួល ទី ១ បើមិនសន្មត នាំឲ្យសហសន្តតិជនអាចពន្យាពេល ដើម្បីទទួលផលជាក់ស្តែងបានច្រើនទោះបីចំណែកមត៌កមិនមានការប្រែប្រួលក៏ដោយ។

បើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលបានដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬបើទ្រព្យនោះត្រូវបានបាត់ ឬវិនាស នៅមុនពេលចាប់ផ្តើមសន្តតិកម្ម តម្លៃនៃប្រទានកម្មត្រូវគណនាតម្លៃនៅពេលចាត់ចែង ឬបាត់បង់ ឬវិនាស។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវចាត់ទុកថាមានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម។ ការប្រាក់ និងផលចំណេញដែលកើតចេញពីប្រទានកម្ម ពុំត្រូវគណនាចូលនៅក្នុងតម្លៃនោះឡើយ[39]។

[39] មាត្រា ១១៦៤ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ឧទាហរណ៍១ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៣០០០ ក្រោយមក C បានលក់ផ្ទះនោះក្នុងតម្លៃ ៥០០០ បន្ទាប់ពីលក់ផ្ទះនោះបានមួយឆ្នាំ A ក៏ស្លាប់។

ផ្អែកលើអង្គហេតុនេះ តម្លៃនៃប្រទានកម្មសម្រាប់ជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ៥០០០ ។

ឧទាហរណ៍២៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៣០០០ ក្រោយមកដី ផ្ទះនោះបានបាក់ស្រុតចោលទៅទន្លេនៅឆ្នាំ ២០១៤ ហើយតាមការវាយតម្លៃដី ផ្ទះនោះនៅឆ្នាំ ២០១៤ គឺមានតម្លៃ ២០០០។ កន្លងបាន ៣ ឆ្នាំ A ក៏ស្លាប់។

ផ្អែកលើអង្គហេតុនេះ តម្លៃនៃប្រទានកម្មសម្រាប់ជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ២០០០។

ឧទាហរណ៍៣៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៣០០០ ក្រោយមក C បានកែសម្រួលនិងធ្វើការនានាលើផ្ទះនោះ ដោយចំណាយអស់ ៥០០០ ហើយបច្ចុប្បន្នផ្ទះ ដីនោះមានតម្លៃ ១០,០០០ ។ បន្ទាប់ពីកែផ្ទះនោះបានមួយឆ្នាំ A ក៏ស្លាប់។

ផ្អែកលើអង្គហេតុនេះ តម្លៃនៃប្រទានកម្មសម្រាប់ជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ៣០០០ ។

ឧទាហរណ៍៤ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យលុយចំនួន ១០,០០០ ដុល្លារអាមេរិក ទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ក្រោយមក C បានយកលុយនោះទៅផ្ញើនៅធនាគារតាមរូបភាព fixed deposit សម្រាប់រយៈពេល ០២ ឆ្នាំ ដោយទទួលបានការប្រាក់ ៩%ឆ្នាំ។ ០៣ ឆ្នាំក្រោយមក A ក៏ស្លាប់។

ផ្អែកលើអង្គហេតុនេះ តម្លៃនៃប្រទានកម្មសម្រាប់ជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ១០,០០០ ។

### ផលប្រយោជន៍ពិសេសលើសតម្លៃនៃចំណែកមត៌ក

ជាគោលការណ៍ ទោះបីជាផលប្រយោជន៍ពិសេសបានទទួលលើសចំណែកមត៌កក៏ដោយ ក៏មិនចាំបាច់បង្វិលសងវិញនោះទេ ហើយចំណែករបស់សន្តតិជនត្រូវសមាមាត្រ។ យោងតាមមាត្រា ១១៦៥ នៃក្រមរដ្ឋប្បវេណី បានប្បញ្ញត្តិថា ទោះបីជាតម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះមិនចាំបាច់បង្វិលមកវិញនូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

ក្នុងករណីដូចមានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់តាមការគណនា ដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកទៅតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដូចមានកំណត់ក្នុងមាត្រា ១១៦៣ ។

ឧទាហរណ៍៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៦000 និងឲ្យលុយនៅធនាគារទៅ D ដែលមានចំនួន ៨000។ មត៌កដែលបន្សល់ទុកគឺ ៧000 ។ ផ្អែកតាមអង្គហេតុនេះ

មត៌កសរុប= ៧000 + ៨000 + ៦000 = ២១ 000

ចំណែកមត៌ករបស់ C = (២១ 000 ៖ ៣) - ៦000= ១000

ណែកមត៌ករបស់ D = (២១ 000 ៖ ៣) - ៨000= -១000

ណែកមត៌ករបស់ B = (២១ 000 ៖ ៣) = ៧000

ប៉ុន្តែ D មិនចាំបាច់បង្វិលសងវិញនោះទេ។ មត៌កជាក់ស្តែងមានតែ ៧000 ហេតុនេះ មិនអាចឲ្យទៅ B ចំនួន ៧000 និង C ចំនួន ១000 នោះទេ នាំឲ្យវិធានសមាមាត្រ ត្រូវបានយកមកអនុវត្ត ដែលមានខ្លឹមសារថា៖

C= (១000×៧000) ៖ ៨000 = ៨៧៥

B= (៧000×៧000) ៖ ៨000 = ៦ ១២៥

**៤.ភាគនៃវិភាគទាន**

ជាប្រព័ន្ធដែលធ្វើឲ្យសន្តតិជនអាចធ្វើសន្តតិកម្មបានច្រើន ដោយសារតែខ្លួនបាន «ធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬដោយការថែទាំព្យាបាលមតកជន ឬដោយវិធីផ្សេងទៀត»។

សហសន្តតិជនអាចធ្វើការពិភាក្សាគ្នាដើម្បីរៀបចំប្រាក់នោះ ឬក្នុងករណីដែលការពិភាក្សាមិនបានសម្រេច ឬការពិភាក្សាមិនអាចធ្វើទៅបាន ត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីសម្រេច។

ឧទាហរណ៍ ក្នុងករណីដែលសន្តតិជន A B និង C ធ្វើសន្តតិកម្មមត៌ក ១000 ដុល្លារដោយបែងចែកស្មើៗគ្នា ហើយ មានការពិភាក្សាគ្នាសម្រេចថា A បានផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ដែលមានតម្លៃស្មើនឹង ៤00 ដុល្លារ (ឬក៏ក្នុងករណីដែលតុលាការបានសម្រេច) ដោយផ្អែកលើការគណនាខាងក្រោម A ត្រូវធ្វើសន្តតិកម្មនូវទឹកប្រាក់ ៦00 ដុល្លារ។

៤00 ដុល្លារ (ភាគនៃវិភាគទាន) + (១000 ដុល្លារ(មត៌ក)) - ៤00 ដុល្លារ(ភាគនៃវិភាគទាន)) ៖ ៣ នាក់ = ៦00 ដុល្លារ។

ករណីដូចខាងក្រោម គឺជាការទទួលស្គាល់ភាគនៃវិភាគទានៈ

– ករណីដែលកូនបានជួយការងារពាណិជ្ជកម្ម ឬកសិកម្មឪពុកម្តាយដែលជាមតកជនដោយមិនយកប្រាក់បៀវត្ស (ប្រាក់ខែ)។

– ករណីដែលប្រពន្ធបានផ្តល់មូលធនសមរម្យសម្រាប់អាជីវកម្មរបស់ប្តី ដែលជាមតកជន។

– ករណីដែលកូនបានថែទាំព្យាបាលឪពុកម្តាយដែលជាមតកជនអស់រយៈពេលវែង(ប៉ុន្តែ ត្រូវកម្រិតត្រឹមតែករណីដែលធ្វើឲ្យមានអានុភាពដល់ទ្រព្យសម្បត្តិ ដូចជា មតកជនអាចសន្សំប្រាក់បាន មិនចាំបាច់ចំណាយថ្លៃអ្នកមើលថែទាំ ជាដើមតែប៉ុណ្ណោះ)។

**កថាភាគទី ៣៖ អ្នកទទួលមត៌កជាជនបរទេស**

សន្តតិជនដែលពុំមានសញ្ជាតិខ្មែរ មិនអាចទទួលសន្តតិកម្មជាដីធ្លីបានឡើយ បើសន្តតិជនទាំងអស់ពុំមានសញ្ជាតិខ្មែរ ដីធ្លីដែលជាចំណែកនៃមត៌កត្រូវក្លាយជានីតិបុគ្គលមត៌ក ដោយសន្តតិជនទាំងអស់នោះ អាចលក់ដីធ្លីក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមត៌ក ក្នុងកំឡុងពេល ០៣(បី) ខែ គិតចាប់ពីថ្ងៃដែលសន្តតិជនទាំងអស់យល់ព្រមជាឯកច្ឆ័ន្ទ (យល់ព្រមទាំងស្រុង ឬមានកម្រិត) ហើយថ្លៃលក់ដីធ្លីនោះ នឹងក្លាយជាមត៌ក នាំឲ្យនីតិបុគ្គលមត៌កត្រូវរលត់។ បើមិនបានចាត់ចែងដីធ្លីនោះ នៅក្នុងអំឡុងពេល ០៣(បី) ខែ នោះទេ កម្មសិទ្ធិចំពោះដីធ្លីនោះ នឹងត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់បន្ទាប់សញ្ជាតិខ្មែរ។ បើសន្តតិជនលំដាប់បន្ទាប់គ្មានសញ្ជាតិខ្មែរនោះទេ នាំឲ្យនត្ថិភាពនៃសន្តតិជន ដែលធ្វើឲ្យដីធ្លីនោះក្លាយជាដីធ្លីគ្មានម្ចាស់ និងចុងក្រោយធ្លាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ។

គួរបញ្ជាក់ថា ប្រសិនបើអ្នកកាន់កាប់មត៌កជាអភ័ព្វបុគ្គល ឬបុគ្គលដែលផ្តាច់មត៌ក ច្បាប់ចាត់ទុកថាការកាន់កាប់នោះ ជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីថ្ងៃចាប់ផ្តើមសន្តតិកម្ម។

## ផ្នែកទី ២៖ សិទ្ធិ និងភាតព្វកិច្ចលើបំណុលនៃសន្តតិកម្ម

### កថាភាគទី ១៖ សិទ្ធិលើបំណុលនៃសន្តតិកម្ម

**១.សិទ្ធិលើបំណុលដែលអាចបែងចែកបាន**

សហសន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិលើបំណុលដែលអាចបែងចែកបានរបស់មតកជន តាមសមាមាត្រានៃចំណែកមត៌កនោះ[40]។

[40] មាត្រា ១១៤៨ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ឧទាហរណ៍៖ មតកជន ក មានសិទ្ធិលើបំណុលចំពោះកូនបំណុល ខ ចំនួន ១០០០០ ដុល្លារ ហើយមតកជន ក មានកូន A និង B។ ករណីមតកជន ក បានទទួលមរណភាពនោះកូន A និងកូន B ត្រូវទទួលបន្តនូវសិទ្ធិលើបំណុលក្នុងម្នាក់ៗចំនួន ៥០០០ ដុល្លារចំពោះកូនបំណុល ខ។

ចំពោះសិទ្ធិលើបំណុលដែលអាចបែងចែកបាន គឺសន្តតិជនអាចយកមកធ្វើជាកម្មវត្ថុនៃការបែងចែកមត៌កបាន។ មានន័យថា នៅក្នុងការពិភាក្សាបែងចែកមត៌ក សន្តតិជនអាចធ្វើការបែងចែកសិទ្ធិលើបំណុលដែលអាចបែងចែកបាន ដោយភាគខុសគ្នានឹងចំណែកមត៌កដែលច្បាប់បានកំណត់។ ដោយសារតែ ទោះបីជាសន្តតិជនណាម្នាក់ទទួលសន្តតិកម្មសិទ្ធិលើបំណុលប៉ុន្មានភាគក៏ដោយ ក៏កូនបំណុលមិនទទួលការខាតប្រយោជន៍ឡើយ។

ឧទាហរណ៍៖ នៅក្នុងករណីសិក្សាខាងលើ កូន A និងកូន B អាចធ្វើតាមខ្លឹមសារនៃការបែងចែកមត៌កបាន ដោយកូន A ទទួលសន្តតិកម្មសិទ្ធិលើបំណុលចំនួន ៨០០០ ដុល្លារហើយកូន B ចំនួន ២០០០ដុល្លារ។

**២.សិទ្ធិលើបំណុលអវិភាគីយ៍**

សិទ្ធិលើបំណុលអវិភាគីយ៍ គឺជាសិទ្ធិលើបំណុលដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ។ សហសន្តតិជន ត្រូវទទួលបន្តសិទ្ធិលើបំណុលអវិភាគីយ៍ ដោយអវិភាគីយ៍[41]។

ឧទាហរណ៍៖ មតកជន ក បានទិញរថយន្តពីមិត្តភក្តិ ខ ហើយបានបង់ប្រាក់រួចរាល់ ប៉ុន្តែមិនទាន់ទទួលបានការប្រគល់រថយន្តពីមិត្តភក្តិ ខ នៅឡើយទេ។ សិទ្ធិលើបំណុលនៃការទទួលការប្រគល់រថយន្ត គឺជាសិទ្ធិលើបំណុលអវិភាគីយ៍។ ករណី មតកជន ក បានទទួលមរណភាព នោះកូន A និង B ត្រូវទទួលបន្តនូវសិទ្ធិលើបំណុលអវិភាគីយ៍នេះ ដោយអវិភាគីយ៍។ ក្នុងករណីនេះ កូន A ឬកូន B មួយណាក៏ដោយ ក៏អាចទាមទារចំពោះមិត្តភក្តិ ខ ឲ្យប្រគល់រថយន្តបានដែរ។

**កថាភាគទី ២៖ កាតព្វកិច្ចលើបំណុលនៃសន្តតិកម្ម**

**១.កាតព្វកិច្ចលើបំណុលដែលអាចបែងចែកបាន**

សហសន្តតិជន ត្រូវទទួលបន្តកាតព្វកិច្ចដែលអាចបែងចែកបានរបស់មតកជន តាមសមាមាត្រនៃចំណែកមត៌កនោះ[42]។

ឧទាហរណ៍៖ មតកជន ក មានកាតព្វកិច្ចចំពោះម្ចាស់បំណុល ខ ចំនួន ១០០០០ ដុល្លារ។ មតកជន ក មានកូន A និងកូន B។ ក្នុងករណីមតកជន ក បានទទួលមរណភាព កូន A និង B នឹងត្រូវទទួលសន្តតិកម្មចំពោះម្ចាស់បំណុល ខ នូវកាតព្វកិច្ចក្នុងម្នាក់ៗចំនួន ៥០០០ ដុល្លារ។

[41] មាត្រា ១១៤៨ នៃក្រមរដ្ឋប្បវេណី

[42] មាត្រា ១១៤៨ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ចំពោះកាតព្វកិច្ចលើបំណុលដែលអាចបែងចែកបាន គឺសន្តតិជនមិនអាចយកមកធ្វើជាកម្មវត្ថុនៃការបែងចែកមត៌កបានទេ។ មានន័យថា សន្តតិជន មិនអាចធ្វើការបែងចែកកាតព្វកិច្ចដែលអាចបែងចែកបាន **ដោយភាគខុសគ្នាជាមួយនឹងចំណែកមត៌កដែលច្បាប់បានកំណត់បានទេ។** ដោយសារតែការទទួលសន្តតិកម្មនូវកាតព្វកិច្ចប៉ុន្មានភាគរបស់សន្តតិជនណាម្នាក់ គឺជាបញ្ហាសំខាន់ចំពោះម្ចាស់បំណុល។ ដូច្នេះត្រូវពិចារណាចំពោះផលប្រយោជន៍របស់ម្ចាស់បំណុល ប្រសិនបើឲ្យសន្តតិជនមានសិទ្ធិសម្រេចចិត្តដោយសេរីនោះនឹងមិនមានភាពយុត្តិធម៌ចំពោះម្ចាស់បំណុលទេ។

ឧទាហរណ៍៖ នៅក្នុងករណីសិក្សាខាងលើ កូន A និងកូន B មិនអាចធ្វើការបែងចែកមត៌កតាមខ្លឹមសារនៃការបែងចែកមត៌កបានទេ ដោយកូន A ទទួលសន្តតិកម្មនូវកាតព្វកិច្ចមានចំនួន ៨០០០ ដុល្លារ ហើយកូន B ចំនួន ២០០០ ដុល្លារនោះទេ។

**២.កាតព្វកិច្ចលើបំណុលអវិភាគីយ៍**

កាតព្វកិច្ចអវិភាគីយ៍ គឺជាកាតព្វកិច្ចដែលមិនអាចបែងចែកបានតាមលក្ខណៈនៃសិទ្ធិ។ សហសន្តតិជនត្រូវទទួលបន្តកាតព្វកិច្ចអវិភាគីយ៍ ដោយអវិភាគីយ៍[43]។

ឧទាហរណ៍៖ មតកជន ក បានលក់រថយន្តរបស់ខ្លួនឲ្យទៅមិត្តភក្តិ ខ ប៉ុន្តែ មិនទាន់ប្រគល់រថយន្តនៅឡើយទេ។ ដូចនេះ មតកជន ក មានកាតព្វកិច្ចប្រគល់រថយន្ត ចំពោះមិត្តភក្តិ ខ។ កាតព្វកិច្ចនេះ គឺជាកាតព្វកិច្ចអវិភាគីយ៍។ ក្រោយពីមតកជន ក បានទទួលមរណភាព នោះកូន A និងកូន B ត្រូវទទួលបន្តកាតព្វកិច្ចអវិភាគីយ៍។ ករណីនេះ មិត្តភក្តិ ខ អាចទាមទារចំពោះ កូន A និងកូន B ម្នាក់ណាក៏បាន ឲ្យធ្វើការប្រគល់រថយន្ត។

[43] មាត្រា ១១៤៨ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី ៣
# ការអនុវត្តសន្តិកម្មតាមច្បាប់

# ជំពូកទី ៣

# ការអនុវត្តសន្តតិកម្មតាមច្បាប់

សន្តតិកម្ម គឺជារបត់មួយ ដែលធ្វើឲ្យផ្លាស់ប្តូរនូវទំនាក់ទំនងគតិយុត្តរវាងមតកជន ដែលបានទទួលមរណភាព និងញាតិរបស់មតកជននោះ ព្រមទាំងឋានៈរបស់ជនទាំងនោះ។ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានទទួលយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិក្នុងសន្តតិកម្ម ដូចនេះសន្តតិជនមានសិទ្ធិក្នុងការសម្រេចចិត្តទទួលយក ឬក៏បោះបង់ចំណែកមត៌ក ទៅតាមការពិចារណារបស់សាមីខ្លួន។ ការទទួលយកនូវគោលការណ៍នេះ គឺដើម្បីធានានៃជីវភាពរបស់អ្នកជំនាន់ក្រោយ ដោយផ្តល់អាទិភាពដល់សន្តតិជនក្នុងការពិចារណា ជៀសវាងក្នុងករណីដែលមានកាតព្វកិច្ចច្រើនជាងសិទ្ធិ និងផលប្រយោជន៍ ក្នុងការបង្ការកុំឲ្យសន្តតិជនទទួលបន្តពេលក្រោយមានវិប្បដិសារី និងមិនអាចទ្រទ្រង់ជីវភាពខ្លួនឯងបានដោយសារតែការទទួលបន្តនូវសន្តតិកម្មនេះ។ ដូច្នេះដើម្បីស្វែងយល់បន្ថែម បន្តពីជំពូកខាងលើឲ្យកាន់តែច្បាស់ និងស៊ីជម្រៅនៅក្នុងជំពូកទី ៣ នេះយើងនឹងបកស្រាយអំពីការអនុវត្តផ្សេងៗ ដែលទាក់ទងទៅនឹងសន្តតិកម្មតាមច្បាប់ ដែលនៅក្នុងផ្នែកទី ១ សិក្សាពី «ការយល់ព្រម និងការបោះបង់នូវសន្តតិកម្ម» ផ្នែកទី ២ សិក្សាពី ភាគបម្រុង។

## ផ្នែកទី ១៖ ការយល់ព្រម និងការបោះបង់នូវសន្តតិកម្ម

### កថាភាគទី ១៖ ការយល់ព្រម

#### ១.ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកនោះ។

ករណីដែលមានចែងនៅក្នុងមាត្រា ១២៥៥ ដូចជា សន្តតិជនបានចាត់ចែងមត៌កជាអាថ៌ ទោះបីជាមិនបង្ហាញឆន្ទៈយល់ព្រមក៏ដោយ ក៏ចាត់ទុកថាបានយល់ព្រមដែរ។ នេះគឺដើម្បីការពារកុំឲ្យភាគីម្ខាងទៀតនៃជំនួញទទួលរងនូវការខូចខាត។ ប្រសិនបើសន្តតិជនមិនបង្កើតអានុភាពនៃការបោះបង់ ឬការយល់ព្រមដោយមានកម្រិតទេនោះ ត្រូវចាត់ទុកថាសន្តតិជននោះបានបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុង ក្រោយពេលមតកជនបានទទួលមរណភាព ចាប់តាំងពីពេលដែលបានដឹងថាសន្តតិកម្មរបស់ខ្លួនបានចាប់ផ្តើម[44]។ លើសពីនេះទៅទៀត នៅក្នុងអំឡុងពេល ៣ខែ ប្រសិនបើ សន្តតិជនបានចាត់ចែងភាគណាមួយនៃមត៌កនោះ ត្រូវចាត់ទុកថាបានបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុង[45]។ ម្យ៉ាងវិញទៀត ទោះបីជានៅក្រោយពេលសន្តតិជនបង្កើត

[44] មាត្រា ១២៥៥ ចំណុច ខ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[45] មាត្រា ១២៥៥ ចំណុច ក ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

អានុភាពនៃការបោះបង់សន្តតិកម្មក៏ដោយ ប្រសិនបើសន្តតិជនលាក់ ឬ ប្រើប្រាស់មត៌កមួយភាគនោះ ត្រូវចាត់ទុកថាបានបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុង[46]។ មាត្រា ១២៥៥ ចំណុច ក ចំណុច ខ និងចំណុច គ នៃក្រមរដ្ឋប្បវេណី ហៅថា «ការយល់ព្រមទាំងស្រុងតាមច្បាប់»។ ប្រសិនបើសន្តតិជនបានយល់ព្រមទាំងស្រុង សន្តតិជននោះត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន[47]។ ដូច្នេះប្រសិនបើសន្តតិជនបានបង្កើតអានុភាពលើការយល់ព្រមទាំងស្រុង មិនថាបំណុលមានចំនួនប៉ុន្មាននោះទេ ក៏សន្តតិជនត្រូវទទួលកាតព្វកិច្ចសងបំណុលទាំងអស់នោះដែរ។

**ប្រសិនបើ សន្តតិជនសងបំណុលដោយការប្រើប្រាស់មត៌ក**

ប្រសិនបើសន្តតិជនមានបំណងចង់បោះបង់សន្តតិកម្ម គាត់មិនត្រូវសងបំណុលដោយប្រើប្រាស់មត៌កនោះទេ។ ប្រសិនបើគាត់ធ្វើបែបនេះ ត្រូវចាត់ទុកថាគាត់បានយល់ព្រមទាំងស្រុងលើសន្តតិកម្ម (មាត្រា ១២៥៥ ចំណុច ក)។

ទោះជាយ៉ាងនេះក្តី អាចនឹងមានករណីដូចខាងក្រោមៈ

សន្តតិជនម្នាក់គិតថានឹងយល់ព្រមទាំងស្រុងលើសន្តតិកម្ម ដូច្នេះហើយ គាត់បានសងបំណុលដោយប្រើប្រាស់មត៌ក។ ប៉ុន្តែក្រោយមក គាត់បានដឹងច្បាស់ថាចំនួនបំណុលមានច្រើនលើសពីការស្មាន ហើយគាត់បានប្តូរចិត្តចង់បោះបង់សន្តតិកម្មនោះវិញ។ នៅក្នុងករណីនេះ ទោះបីជាសន្តតិជនបានប្រើប្រាស់មត៌កដើម្បីសងបំណុលក៏ដោយ គាត់មិនត្រូវបានចាត់ទុកថាបានយល់ព្រមទាំងស្រុងលើសន្តតិកម្មនោះទេ។ មូលហេតុ គឺដោយសារតែ មាត្រា ១២៥៥ ចំណុច ក មិនយកមកអនុវត្តក្នុង មាត្រា ១២៥១ កថាខណ្ឌទី ២ ឡើយ។

**២.ការយល់ព្រមដោយមានកម្រិត**

សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនបានត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ[48]។ នេះហៅថា ការយល់ព្រមដោយមានកម្រិត។ ប្រសិនបើមានភាពច្បាស់លាស់ថា មានកាតព្វកិច្ចច្រើនជាងទ្រព្យសម្បត្តិ សន្តតិជនអាចធ្វើការសម្រេចចិត្តដើម្បីបោះបង់សន្តតិកម្មបាន។ ប៉ុន្តែ ក៏អាចមានករណីដែលមិនដឹងច្បាស់ពីចំនួននៃកាតព្វកិច្ចផងដែរ។ ក្នុងករណីដូចនេះ សន្តតិជនអាចនឹងចង់ដឹងថា តើចំនួនកាតព្វកិច្ចមានលើសសិទ្ធិដែរឬទេ? ប្រសិនបើសន្តតិជនយល់ព្រមដោយមានកម្រិតនឹងត្រូវសងបំណុលនោះដោយប្រើប្រាស់មត៌ក។ ក្រោយពីការសង

[46] មាត្រា ១២៥៥ ចំណុច គ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[47] មាត្រា ១២៥៤ នៃក្រមរដ្ឋប្បវេណី

[48] មាត្រា ១២៥៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី

ប្រសិនបើមាននៅសល់ទ្រព្យសម្បត្តិ សន្តតិជនអាចទទួលយកទ្រព្យសម្បត្តិនោះបាន។ ផ្ទុយទៅវិញ ប្រសិនបើមាននៅសល់បំណុលក្រោយពីការសង សន្តតិជនគ្មានកាតព្វកិច្ចសងបំណុលនោះឡើយ។

**កថាភាគទី ២៖ ការបោះបង់**

**១.របៀបនៃការបោះបង់សន្តតិកម្ម**

**ក.ការដាក់ពាក្យសុំ**

សន្តតិជនត្រូវដាក់ពាក្យសុំបោះបង់សន្តតិកម្មទៅកាន់តុលាការ ដើម្បីបង្កើតអានុភាពនៃការបោះបង់សន្តតិកម្ម[49]។ តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម[50]។

ការដាក់ពាក្យសុំបោះបង់សន្តតិកម្ម ត្រូវធ្វើឡើងដោយសន្តតិជនម្នាក់ៗ។ ដូចនេះ អ្នកដាក់ពាក្យមិនចាំបាច់ដាក់ពាក្យសុំជាមួយសន្តតិជនដ៏ទៃ ឬមិនចាំបាច់មានការយល់ព្រមពីសន្តតិជនដ៏ទៃនោះឡើយ។ លើសពីនេះទៀត ថ្វីត្បិតតែសន្តតិជនម្នាក់បានធ្វើការយល់ព្រមទាំងស្រុងលើសន្តតិកម្មក៏ដោយ ក៏សន្តតិជនផ្សេងទៀតនៅតែអាចធ្វើការបោះបង់សន្តតិកម្មបានដែរ។

**ខ.ករណីដែលសន្តតិជនជាអនីតិជន ឬជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ**

ប្រសិនបើ សន្តតិជនជាអនីតិជន ឬជាជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ សន្តតិជននោះមិនអាចដាក់ពាក្យសុំដោយខ្លួនឯងបាននោះទេ លើកលែងតែជាអនីតិជនដែលបានទទួលអគ្គាធិនភាពតែប៉ុណ្ណោះ។ ថ្វីត្បិតតែសន្តតិជននោះ បានទទួលការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបាអាណាព្យាបាលរបស់អនីតិជន ឬអាណាព្យាបាលទូទៅ) ក៏ដោយ ក៏សន្តតិជននោះមិនអាចដាក់ពាក្យសុំដោយខ្លួនឯងបានដែរ។ ដើម្បីអាចឲ្យសន្តតិជននោះអាចបោះបង់សន្តតិកម្មបាន អ្នកតំណាងដែលច្បាប់បានកំណត់ត្រូវដាក់ពាក្យសុំ[51]។ ប្រសិនបើ បានតែងតាំងអ្នកត្រួតពិនិត្យសម្រាប់អាណាព្យាបាលទូទៅ ឬអាណាព្យាបាលរបស់អនីតិជន នោះអាណាព្យាបាលទូទៅ ឬអាណាព្យាបាលរបស់អនីតិជនត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យនោះជាមុនសិន[52]។

**គ.ករណីដែលសន្តតិជនជាជននៅក្រោមហិតូបត្ថម្ភ**

[49] មាត្រា ១២៦០ នៃក្រមរដ្ឋប្បវេណី

[50] មាត្រា ៣ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង និងឧបសម្ព័ន្ធផ្នែកទី ៥ ចំណុចទី ១៤

[51]មាត្រា ១៧ កថាខណ្ឌទី ២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

[52] មាត្រា ១០៩០ និងមាត្រា ១១២៦ នៃក្រមរដ្ឋប្បវេណី

សន្តតិជនអាចដាក់ពាក្យសុំដោយខ្លួនឯងបាន ប៉ុន្តែត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ[53]។ មួយវិញទៀត ហិតូបត្ថម្ភកៈមិនអាចដាក់ពាក្យសុំក្នុងនាមជាជននៅក្រោមហិតូបត្ថម្ភនោះទេ ដោយសារតែហិតូបត្ថម្ភកៈមិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ។

**២.ការដាក់កម្រិតរយៈពេលដាក់ពាក្យសុំ**

ប្រសិនបើសន្តតិជនចង់បោះបង់សន្តតិកម្ម គាត់ត្រូវដាក់ពាក្យសុំបោះបង់ទៅកាន់តុលាការក្នុងអំឡុងពេល ៣ខែ ក្រោយពីបានដឹងថាសន្តតិកម្មរបស់ខ្លួនបានចាប់ផ្តើម។ អំឡុងពេល ៣ខែនេះហៅថា អំឡុងពេលគិតពិចារណា។ ពីព្រោះតែសន្តតិជនម្នាក់ៗបានដឹងអំពីការចាប់ផ្តើមសន្តតិកម្មនៅពេលខុសៗគ្នា ដូចនេះអំឡុងពេលសម្រាប់គិតពិចារណា ក៏ត្រូវគណនាសម្រាប់សន្តតិជនម្នាក់ៗដោយអំឡុងពេលខុសៗគ្នាផងដែរ។ ដូច្នេះ ទោះបីជារយៈពេលសម្រាប់គិតពិចារណារបស់សន្តតិជនខ្លះបានចប់ក៏ដោយ ក៏សន្តតិជនផ្សេងទៀត នៅតែអាចបោះបង់ចោលសន្តតិកម្មបានផងដែរ។

នៅក្នុងអំឡុងពេលគិតពិចារណា សន្តតិជនត្រូវស្រាវជ្រាវពី សិទ្ធិ និងកាតព្វកិច្ចហើយត្រូវសម្រេច ថាតើត្រូវបោះបង់សន្តតិកម្ម ត្រូវយល់ព្រមដោយមានកម្រិត ឬយល់ព្រមទាំងស្រុង? ប្រសិនបើគាត់មិនបានដាក់ពាក្យសុំបោះបង់ ឬយល់ព្រមដោយមានកម្រិតទេនោះ ត្រូវចាត់ទុកថាគាត់បានយល់ព្រមទាំងស្រុងលើសន្តតិកម្មនោះ[54]។

**ក.ករណីសន្តតិជនទទួលមរណភាពដោយមិនបានយល់ព្រម ឬបោះបង់**

ប្រសិនបើសន្តតិជនទទួលមរណភាព ដោយមិនបានធ្វើការយល់ព្រម ឬបោះបង់នោះអំឡុងពេលគិតពិចារណាត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជននៃសន្តតិជនដែលបានទទួលមរណភាពនោះ បានដឹងថាសន្តតិកម្មរបស់ខ្លួនបានចាប់ផ្តើម[55]។

ឧទាហរណ៍៖ A ជាមតកជន B ជាសន្តតិជន និង C ជាកូនរបស់ B។ A បានទទួលមរណភាពនៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០១៦។ B បានទទួលមរណភាពនៅថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១៦ ដោយមិនបានយល់ព្រម ឬបោះបង់សន្តតិកម្មឡើយ។ Cបានដឹងពីការស្លាប់របស់ B នៅថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៦។ ក្នុងករណីនេះ អំឡុងពេលគិតពិចារណាសម្រាប់ការទទួលសន្តតិកម្មពី A ត្រូវគណនាចាប់ពី ថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៦ តទៅ[56]។ អំឡុងពេលគិតពិចារណាសម្រាប់ការទទួលសន្តតិកម្មពី B ត្រូវគណនាពី ថ្ងៃទី ១៥ ខែសីហា

[53] មាត្រា ៣០ ចំណុច គ និង ង នៃក្រមរដ្ឋប្បវេណី និងមាត្រា ១៧ កថាខណ្ឌទី ៤ និង ៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[54] មាត្រា ១២៥៥ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ស្តីពីការយល់ព្រមទាំងស្រុងតាមច្បាប់

[55] មាត្រា ១២៤៩ នៃក្រមរដ្ឋប្បវេណី

[56] មាត្រា ១២៤៩ នៃក្រមរដ្ឋប្បវេណី

ឆ្នាំ ២០១៦ ដូចគ្នា(មាត្រា ១២៤៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ C អាចគិតពិចារណាថា ត្រូវបោះបង់ ឬក៏អត់ រហូតដល់ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៦។ ប្រសិនបើ C បោះបង់សន្តតិកម្មពី B នោះ C មិនចាំបាច់ពិចារណាលើសន្តតិកម្មពី A ឡើយ។ ផ្ទុយទៅវិញ ប្រសិនបើ C យល់ព្រមសន្តតិកម្មពី B នោះ C ត្រូវពិចារណាបន្ថែម ថាតើត្រូវបោះបង់ ឬយល់ព្រមទទួលសន្តតិកម្មពី A។

**ខ.ករណីដែលសន្តតិជនជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ**

ប្រសិនបើសន្តតិជនជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលគិតពិចារណា ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាង ដែលច្បាប់បានកំណត់បានដឹងថាសន្តតិកម្មចំពោះជនដែលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ បានចាប់ផ្ដើម[57]។ ប្រសិនបើ សន្តតិជនដែលជាអនីតិជន គ្មានទាំងអ្នកមានអំណាចមេបា ឬអាណាព្យាបាលទេនោះ អំឡុងពេលគិតពិចារណា ត្រូវគណនាដោយគិតចាប់ពីក្រោយពេលដែលបានតែងតាំងអាណាព្យាបាលសម្រាប់អនីតិជន។

**គ.ករណីដែលសន្តតិជនមិនបានដឹងពីអត្ថិភាពនៃកាតព្វកិច្ច**

ក្នុងករណីដែលមតកជនមានកាតព្វកិច្ចច្រើនលើសលប់ ដែលមិនអាចយកសិទ្ធិទៅសងឲ្យគ្រប់ចំនួនបានទេនោះ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច តាមស្ថានភាពនៃជីវភាពរបស់មតកជន ឬស្ថានភាពទ្រព្យសម្បត្តិរបស់មតកជន និងស្ថានភាពផ្សេងៗទៀតទេនោះ អំឡុងពេលគិតពិចារណា ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជន បានដឹងពីអត្ថិភាពនៃកាតព្វកិច្ចនោះ[58]។ ក្នុងករណីនេះ ប្រសិនបើសន្តតិជនបានចាត់ចែងទ្រព្យដែលជាមត៌កណាមួយ ដើម្បីសងកាតព្វកិច្ចរបស់មតកជន នៅមុនពេលដែលខ្លួនបានដឹងពីអត្ថិភាពនៃកាតព្វកិច្ចដែលបានរៀបរាប់ខាងលើ មាត្រា ១២៥៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តឡើយ មានន័យថា សន្តតិជននៅតែអាចបោះបង់សន្តតិកម្មបានជានិច្ច។

**ឃ.ការពន្យារពេលគិតពិចារណា**

ក្នុងករណីដែលមានសិទ្ធិ ឬកាតព្វកិច្ចច្រើន អំឡុងពេល ៣ខែ ប្រហែលជាមិនគ្រប់គ្រាន់សម្រាប់កំណត់ថាត្រូវបោះបង់សន្តតិកម្ម ឬអត់នោះទេ។ ករណីនេះ សន្តតិជនអាចដាក់ពាក្យសុំពន្យារពេលបាន[59]។ ពាក្យសុំពន្យារអំឡុងពេលគិតពិចារណាត្រូវដាក់ទៅតុលាការនៅក្នុងអំឡុងពេលគិតពិចារណានោះ។ ប្រសិនបើតុលាការទទួលបានពាក្យសុំនោះ តុលាការត្រូវពិចារណាលើចំណុចដូចជា ចំនួន និងប្រភេទនៃមត៌ក និង

[57] មាត្រា ១២៥០ នៃក្រមរដ្ឋប្បវេណី

[58] មាត្រា ១២៥១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី

[59] មាត្រា ១២៤៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី និងមាត្រា ៣នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង និងឧបសម្ព័ន្ធផ្នែកទី ៥ចំណុចទី១១

កាតព្វកិច្ច ទីកន្លែងចាប់ផ្ដើមសន្តតិកម្ម ទីកន្លែងដែលសហសន្តតិជនរស់នៅ ជាដើម។ ប្រសិនបើតុលាការយល់ថាគួរផ្ដល់ឲ្យការពន្យារ តុលាការត្រូវចេញដីកាសម្រេចពន្យារអំឡុងពេលគិតពិចារណា។

បញ្ហាស្ថិតត្រង់ថា ប្រសិនបើការពន្យារអំឡុងពេលនោះនៅតែមិនគ្រប់គ្រាន់ តើសន្តតិជនអាចដាក់ពាក្យសុំពន្យារពេលលើកទី ២បានដែរឬទេ? សន្តតិជន អាចដាក់ពាក្យសុំជាលើកទី ២បានពីព្រោះ ក្រមរដ្ឋប្បវេណីមិនបានកម្រិតពេលវេលានៃការពន្យារនោះទេឡើយ។ ពាក្យសុំទី២ នោះត្រូវដាក់នៅក្នុងអំឡុងពេលដែលបានពន្យារដោយដីការសម្រេចនៃពាក្យសុំទី ១។

**កថាភាគទី ៣៖ អានុភាព**

**១.អានុភាពនៃការយល់ព្រមដោយកម្រិត**

**ក.ការជម្រះបញ្ជីមត៌ក**

ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយមានកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចទាមទារឲ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ[60]។ ជារួម មត៌កត្រូវបែងចែកឲ្យដាច់ពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន។ កាតព្វកិច្ច និង អច្ច័យទាននឹងត្រូវដកចេញពីមត៌កតែប៉ុណ្ណោះដោយផ្អែកតាមមាត្រា ១២៨០ ដល់មាត្រា ១២៨៩ នៃក្រមរដ្ឋប្បវេណី។ ក្រោយពីបានសងបំណុល និងធ្វើអច្ច័យទានគ្រប់អស់ហើយ ប្រសិនបើ ទ្រព្យសម្បត្តិមាននៅសល់ សន្តតិជនអាចទទួលបានទ្រព្យសម្បត្តិនោះ។ ផ្ទុយទៅវិញ ប្រសិនបើមិនមានទ្រព្យសម្បត្តិគ្រប់គ្រាន់សម្រាប់សងកាតព្វកិច្ច និងធ្វើអច្ច័យទានទេនោះ ម្ចាស់បំណុល និង អច្ច័យលាភី មិនអាចទទួលបានការសងដ៏ពេញលេញមួយបានឡើយ។

ប្រសិនបើម្ចាស់បំណុល (ដើមចោទ) បានដាក់ពាក្យបណ្ដឹងចំពោះសន្តតិជន (ចុងចម្លើយ) ដែលបានយល់ព្រមដោយមានកម្រិត ហើយម្ចាស់បំណុលជាអ្នកឈ្នះ សាលក្រមត្រូវបញ្ជាក់ឲ្យច្បាស់ថាចុងចម្លើយត្រូវទទួលបន្ទុកកាតព្វកិច្ចត្រឹមកម្រិតនៃមត៌កដែលខ្លួនទទួលបានតែប៉ុណ្ណោះ។ ឧទាហរណ៍៖ នៅក្នុងសេចក្ដីសម្រេចបញ្ចប់៖ «ចុងចម្លើយត្រូវបង់ប្រាក់ចំនួន ១000$ ទៅឲ្យដើមចោទតាមកម្រិតនៃទ្រព្យសម្បត្តិដែលចុងចម្លើយទទួលបន្តពីលោក X»។

**ខ.ការទទួលខុសត្រូវរបស់សន្តតិជនដែលបានបំពានលើការយល់ព្រមដោយមានកម្រិត**

ក្រោយពីបានបង្កើតអានុភាពនៃការយល់ព្រមដោយមានកម្រិត ប្រសិនបើ សន្តតិជនមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬមួយភាគទៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬបានចាត់ចែងភាគណាមួយនៃទ្រព្យសម្បត្តិ ឬលាក់ ឬប្រើប្រាស់ភាគណាមួយនៃទ្រព្យសម្បត្តិជាលក្ខណៈឯកជន នោះសន្តតិជនរូបនោះនឹងត្រូវចាត់

[60] មាត្រា ១២៥៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី

ទុកថាបានយល់ព្រមទាំងស្រុង។ នៅក្នុងករណីនេះ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសន្តតិជននោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលពុំអាចទទួលការសងដោយមត៌កបាន[61]។

**២.អានុភាពនៃការបោះបង់**

ប្រសិនបើ តុលាការគិតថាពាក្យសុំបោះបង់សន្តតិកម្មមានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចដើម្បីទទួលយកពាក្យសុំបោះបង់សន្តតិកម្ម។

តុលាការត្រូវពិនិត្យថា អ្នកដែលបានដាក់ពាក្យសុំ គឺជាសន្តតិជនពិតប្រាកដដែរឬទេ តើបានដាក់ពាក្យសុំក្នុងអំឡុងពេលគិតពិចារណាដែរឬទេ តើអ្នកដាក់ពាក្យសុំពិតជាមានបំណងចង់បោះបង់សន្តតិកម្មដែរឬទេ ថាតើមានមូលហេតុសម្រាប់ការយល់ព្រមទាំងស្រុងតាមច្បាប់ដែរឬទេ?[62]។ ម្យ៉ាងវិញទៀត មូលហេតុត្រឹមត្រូវ ឬភាពចាំបាច់ក្នុងការបោះបង់ មិនមែនជាល័ក្ខខ័ណ្ឌក្នុងការបោះបង់សន្តតិកម្មនោះទេ។ ដូចនេះ តុលាការមិនត្រូវលើកចោលពាក្យសុំនោះឡើយ ទោះបីជាគ្មានមូលហេតុ ឬភាពចាំបាច់នៃការបោះបង់ក៏ដោយ។

ច្បាប់មិនតម្រូវឲ្យតុលាការ ដឹងឮពីគំនិតរបស់អ្នកដាក់ពាក្យសុំនោះទេ។ ប៉ុន្តែ ដើម្បីជាការអនុវត្តដ៏ល្អនោះ តុលាការគួរពិនិត្យលើអ្នកដាក់ពាក្យសុំដោយផ្ទាល់ ឬយ៉ាងហោចណាស់ ពិនិត្យតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើការបញ្ជាក់ថាជា ឆន្ទៈពិតរបស់អ្នកដាក់ពាក្យសុំ។

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក[63]។ ដូច្នេះហើយ បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូង។ រីឯចំនួនមត៌កដែលសហសន្តតិជនអាចទទួលបានអាចនឹងមានការកើនឡើង ពីព្រោះចំនួននៃសន្តតិជននឹងត្រូវបានកាត់បន្ថយដោយសារតែការបោះបង់ចោលសន្តតិកម្មរបស់សន្តតិជនណាម្នាក់។ ប្រសិនបើ សន្តតិជនទាំងអស់បោះបង់សន្តតិកម្ម សន្តតិជនដែលស្ថិតនៅលំដាប់បន្ទាប់ ត្រូវទទួលសិទ្ធិ និងទទួលបន្ទុកកាតព្វកិច្ច[64]។ យ៉ាងណាមិញ ទោះបីជាសន្តតិជនបានបោះបង់សន្តតិកម្មក៏ដោយ សន្តតិកម្មជំនួសនឹងមិនកើតឡើងនោះទេ[65]។ ដូច្នេះហើយ ញាតិលោហិតខ្សែផ្ទាល់នៃសន្តតិជនដែលបានបោះបង់សន្តតិកម្ម មិនអាចទទួលមត៌កតាមរយៈសន្តតិកម្មជំនួសបានឡើយ។

## ផ្នែកទី ២៖ ភាគបម្រុង

### កថាភាគទី ១៖ និដ្ឋភាពទូទៅនៃភាគបម្រុង

[61] មាត្រា ១២៥៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី

[62] មាត្រា ១២៥៥ នៃក្រមរដ្ឋប្បវេណី

[63] មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណី

[64] ស្ដីពី លំដាប់នៃសន្តតិកម្ម មើលមាត្រា ១២៥៦ មាត្រា ១១៥៩ និងមាត្រា ១១៦០ នៃក្រមរដ្ឋប្បវេណី

[65] មាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណី មិនបានចែងអំពីករណីបោះបង់សន្តតិកម្មឡើយ

ដោយសារក្រមរដ្ឋប្បវេណីកម្ពុជា ទទួលស្គាល់នូវរបបសន្តតិកម្មតាមច្បាប់ផង និង សន្តតិកម្មតាមបណ្តាំផង ទើបអាចបង្កើតឲ្យមានស្ថានភាពពីរគឺ ៖

១-តាមរយៈសន្តតិកម្មតាមច្បាប់ ទាយាទទាំងអស់របស់មតកជន នឹងត្រូវទទួលបាន នូវចំណែកមរតក ដែលចំណែកមរតកនេះ ត្រូវបានកំណត់ និងធានាដោយវិធានច្បាប់។

២-ចំណែកមរតករបស់ទាយាទ ដែលត្រូវបានធានាដោយវិធានច្បាប់ ដូចខាងលើ នឹងត្រូវបាត់បង់ ឬបំពាន ដោយសន្តតិកម្មតាមបណ្តាំ (មតកសាសន៍) ឬការចាត់ចែងទ្រព្យ របស់មតកជន ពេលនៅរស់។

ដើម្បីសម្របសម្រួលនូវស្ថានភាពទាំងពីរនេះ ទើបក្រមរដ្ឋប្បវេណី បានបង្កើតនូវរបប ភាគបម្រុងដើម្បីកំណត់នូវចំណែកមរតកអប្បបរមា សម្រាប់បម្រុងទុកឲ្យ សន្តតិជនមួយចំនួន ក្នុងករណីដែលមតកជន បានធ្វើការចាត់ចែងទ្រព្យតាមឆន្ទៈរបស់ខ្លួន ទៅឲ្យជនដទៃក្រៅពីសន្តតិជន ឬចាត់ចែងទ្រព្យសម្បត្តិមួយភាគធំ ឲ្យទៅសន្តតិជនមួយចំនួន ដោយធ្វើឲ្យសន្តតិជនមួយចំនួនផ្សេងទៀត ទទួលបានចំណែកមរតកក្នុងបរិមាណតិចតួច មិនសមហេតុសមផល ឬពុំទទួលបានចំណែកអ្វីសោះតែម្តង។

តួយ៉ាង ក្រមរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្ន មិនមានមាត្រាណាមួយកំណត់និយមន័យ ជាក់លាក់អំពី អ្វីទៅជា «ភាគបម្រុង» នោះឡើយ។ ប៉ុន្តែបើយើងសិក្សាទៅលើក្រមរដ្ឋប្បវេណី ឆ្នាំ ១៩៦៧ ឃើញថាបានឲ្យ និយមន័យដូច្នេះថា ៖ «ភាគបម្រុង គឺជារបបមួយនៃបេតិកភណ្ឌ ដែលម្ចាស់បណ្តាំខ្លួនឯងផ្ទាល់ ក៏មិនអាចនឹងចាត់ចែងយ៉ាងណាៗ ដោយសេរីបានឡើយ»[66]។

ទោះបីជាក្រមរដ្ឋប្បវេណីមិនបានឲ្យនិយមន័យនៃរបបភាគបម្រុងនេះក៏ដោយតែយើងអាចកំណត់អំពីអត្ថន័យនៃរបបនេះតាមរយៈការសិក្សាលើមាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណី **ភាគបម្រុង** គឺជាសិទ្ធិដែលទទួលបានមត៌កជាអប្បបរមាដែលត្រូវធានាដោយច្បាប់ចំពោះអ្នកមានសិទ្ធិលើភាគបម្រុង។

បញ្ញត្តិស្តីពីភាគបម្រុង ត្រូវបានបង្កើតឡើង ក្នុងគោលបំណងដូចខាងក្រោម៖

- ធានានូវចំណែកមរតកអប្បបរមាចំពោះសន្តតិជនមួយចំនួន (ញាតិជិតស្និទ្ធិនឹង មតកជន)។

- អនុញ្ញាតឲ្យសន្តតិជនមួយចំនួន (អ្នកមានសិទ្ធិលើភាគបម្រុង) បដិសេធនូវសេរីភាពមួយផ្នែក ដែលជាឆន្ទៈរបស់មតកជននៅក្នុងមតកសាសន៍។

មួយវិញទៀត ការកំណត់អំពីភាគបម្រុង មានផលប្រយោជន៍ដូចខាងក្រោម៖

-ដើម្បីជាប្រយោជន៍ដល់ការសម្របសម្រួលរវាងសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។

ទំព័រ ៣២-រក្សានូវចំណែកមត៌កជាក់លាក់លើទ្រព្យសម្បត្តិរបស់មតកជន សម្រាប់ជន ដែលបានរស់នៅក្នុងបន្ទុក។

[66] មាត្រា ៥២៨ ក្រមរដ្ឋប្បវេណី ឆ្នាំ ១៩៦៧

-ដោះស្រាយនូវចំណែកមត៌កជាសក្តានុពលសម្រាប់ញាតិជិតស្និទ្ធិ ដែលបានចូលរួមក្នុងការបង្កើតទ្រព្យសម្បត្តិរបស់មតកជន។

**១.ជនដែលមានសិទ្ធិលើភាគបម្រុង**

ក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់យកជនមួយចំនួនដែលជាប់ទំនាក់ទំនងញាតិយ៉ាងជិតស្និទ្ធិជាមួយនឹងមតកជន ជាអ្នកមានសិទ្ធិលើភាគបម្រុង។

អ្នកមានសិទ្ធិលើភាគបម្រុងរួមមានៈ

-បច្ឆាញាតិផ្ទាល់ ឬសន្តតិជនជំនួសរបស់ពួកគេ (កូនរបស់កូនសន្តតិជន អាចក្លាយជាសន្តតិជនជំនួស)។

-ឳពុកម្តាយ និងជីដូនជីតា

-សហព័ទ្ធ។

ដោយឡែកចំពោះបងប្អូនបង្កើត (សន្តតិជនលំដាប់ទី ៣) និងសន្តតិជនតាមច្បាប់ ដទៃទៀត ពុំមានភ័ព្វជាអ្នកមានសិទ្ធិលើភាគបម្រុងនោះទេ។

ខ្លឹមសារខាងលើនេះ គឺឆ្លុះបញ្ចាំងនូវទំនាក់ទំនងនៃការកំណត់លំដាប់សន្តតិជន ដែលយើងគប្បីដឹងថាសន្តតិជនលំដាប់ណាខ្លះដែលមានសិទ្ធិលើភាគបំរុង ហើយសន្តតិជនដែលនៅលំដាប់បន្ទាប់អាចទទួលបានសិទ្ធិលើភាគបម្រុងដែរ ឬទេ?

នៅក្នុងចំណោមសន្តតិជនដែលរួមមាន បច្ឆាញាតិផ្ទាល់ ឳពុក ម្តាយ ជីដូន ជីតា និងសហព័ទ្ធ គឺមានតែសន្តតិជន នៅក្នុងលំដាប់ដែលត្រូវទទួលមរតកប៉ុណ្ណោះ ទើបមានសិទ្ធិលើភាគបម្រុង។

-កូនរបស់មតកជនជាសន្តតិជនលំដាប់ទី ១ រួមទាំងសន្តតិជនជំនួសរបស់ពួកគេផងដែរ[67]។

-បើពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជនជាសន្តតិជន (សន្តតិជនលំដាប់ទី ២)[68]។

-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជន បងប្អូនបង្កើតរបស់មតកជនត្រូវក្លាយជាសន្តតិជន (សន្តតិជនលំដាប់ទី ៣)[69]។

-សហព័ទ្ធរបស់មតកជន ជាសន្តតិជនជានិច្ច[70]។

[67] មាត្រា ១១៥៦ និងមាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណី

[68] មាត្រា ១១៥៨ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[69] មាត្រា ១១៦០ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[70] មាត្រា ១១៦១ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ជាគោលការណ៍ក្រមរដ្ឋប្បវេណីទទួលស្គាល់អ្នកទាំងនេះ ជាសន្តតិជនដែលត្រូវទទួលបន្តនូវមត៌ករបស់សាច់ញាតិដែលបានស្លាប់ទៅហើយនោះ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏មិនមានន័យថាអ្នកទាំងអស់នោះ នឹងទទួលបាននូវចំណែកមត៌កគ្រប់ៗគ្នា នោះដែរ។ ច្បាប់បានបញ្ញត្តិនូវលំដាប់នៃការទទួលទ្រព្យសម្បត្តិដែលជាមត៌កនៃមតកជន ដោយកំណត់យកបច្ឆាញាតិផ្ទាល់របស់មតកជន ជាអ្នកមានសិទ្ធិទទួលបានមត៌កមុនគេ។ ក្នុងករណីដែលមតកជនគ្មានបច្ឆាញាតិផ្ទាល់ទាល់តែសោះ នោះមត៌ករបស់មតកជន នឹងត្រូវទទួលបន្តដោយបុព្វញាតិផ្ទាល់របស់មតកជននោះ។ ចំពោះ សន្តតិជនលំដាប់ទី ៣ វិញ លុះត្រាតែមតកជននោះគ្មានបច្ឆាញាតិ ហើយបុព្វញាតិក៏គ្មាន នោះទើបខ្លួនអាចទទួលបានឋានៈជាសន្តតិជន។

ដោយឡែកសហព័ទ្ធរបស់មតកជន ជាជនដែលមានភ័ព្វ ទទួលបានឋានៈជាសន្តតិជនជានិច្ចទោះជាមានសន្តតិជនលំដាប់ណាក៏ដោយ ក៏សហព័ទ្ធនៅតែទទួលបានឋានៈជាសន្តតិជនដដែល។

ចំពោះភាគបម្រុង អ្នកដែលមានសិទ្ធិ គឺមានតែសន្តតិជនលំដាប់ទី ១ ទី ២ (កំណត់ត្រឹមបុព្វញាតិផ្ទាល់ថ្នាក់ទី ២) និង សហព័ទ្ធតែប៉ុណ្ណោះ។ ប៉ុន្តែទោះជាយ៉ាងនេះ ក៏ដោយ ក៏មិនមានន័យថាជនទាំងអស់នេះទទួលបានសិទ្ធិលើភាគ បម្រុងគ្រប់គ្នានោះដែរ ពោលគឺអ្នកមានសិទ្ធិលើភាគបម្រុង ត្រូវអនុវត្តទៅតាមលំដាប់នៃសន្តតិជនដូចខាងក្រោម៖

-សហព័ទ្ធ មានសិទ្ធិលើភាគបម្រុងជានិច្ច។

-បើមានសន្តតិជនលំដាប់ទី ១ ជាអ្នកមានសិទ្ធិលើភាគបម្រុងហើយនោះ សន្តតិជនលំដាប់ទី ២ ពុំមានសិទ្ធិទទួលឋានៈជាអ្នកមានសិទ្ធិលើភាគបម្រុងទៀតនោះឡើយ។

**២.ការកំណត់អំពីចំណែកនៃភាគបម្រុង**

-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជា ឪពុកម្តាយ ឬជីដូនជីតា ប៉ុណ្ណោះ។

-១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង។

ក្នុងករណីដែលសន្តតិជនដែលមានសិទ្ធិលើភាគបម្រុងច្រើននាក់ អ្នកមានសិទ្ធិម្នាក់ៗអាចទទួលបានចំណែកលើភាគបម្រុងតាមសមាមាត្រនៃចំណែកមត៌ក ដែលខ្លួនត្រូវទទួលបានតាមច្បាប់។

យើងឃើញថាច្បាប់បានកំណត់យកចំណែក ១/៣ ជាភាគបម្រុងសម្រាប់សន្តតិជនជាឪពុកម្តាយ ឬជាជីដូនជីតា ប៉ុន្តែសូមពិនិត្យមើលលើឃ្លា «ក្នុងករណីមានតែសន្តតិជនជាឪពុកម្តាយ ឬជីដូនជីតា»។ ហើយចំណែក ១/២ នៃទ្រព្យសម្បត្តិរបស់មតកជនក្នុងករណីផ្សេងៗ មានន័យថា ក្នុងករណីដែលគ្មានសន្តតិជនជាសហព័ទ្ធ ហើយមានតែឪពុកម្តាយ ឬមានតែជីដូនជីតា នោះចំណែកភាគបម្រុងត្រូវផ្តល់ឲ្យ ១/៣ (មួយភាគបី) តែបើមានសន្តតិជនផ្សេង ដូចជាកូន ឬសហព័ទ្ធ នោះភាគនៃភាគបម្រុងត្រូវគិត ១/២ (មួយភាគពីរ)។

ខាងក្រោមនេះយើងខ្ញុំនឹងបង្ហាញអ្នកទាំងអស់គ្នានូវឧទាហរណ៍ខ្លះៗអំពីបញ្ហាទាំងអស់ខាងលើ។

**ឧទាហរណ៍ទី១** លោក A មានកូនប្រុសម្នាក់ C និង B ជាសហព័ទ្ធ។ ក្នុងករណីនេះ សន្តតិជន របស់ A មានតែកូនម្នាក់ C និងសហព័ទ្ធ B នាំឲ្យភាគបម្រុងរបស់អ្នកទាំងពីរនេះ គឺ ១/២ នៃទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង។

ហើយចំណែកភាគបម្រុងរបស់សន្តតិជនម្នាក់ៗ ស្មើនឹង ១/៤ ។ ក្នុងករណីនេះ ប្រសិនបើ C ទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្មនោះ កូនរបស់ C (ចៅរបស់ មតកជន A )ក៏ទទួលបានឋានៈជាអ្នកមានសិទ្ធិលើភាគបម្រុងផង ដែរតាមរយៈសន្តតិកម្ម ជំនួស[71]។

**ឧទាហរណ៍ទី២** លោក A មិនទាន់រៀបការ ពុំមានកូន មានតែឪពុក និងម្តាយ។ ដូច្នេះសន្តតិជនដែលមានសិទ្ធិលើភាគបម្រុង គឺ ឪពុក-ម្តាយ ក្នុងករណីនេះ ភាគនៃភាគបម្រុងគឺស្មើ ១/៣ នៃទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង។ ដោយសន្តតិជនមានពីរនាក់ នាំឲ្យ ចំណែកនៃភាគបម្រុងម្នាក់ ស្មើនឹង ១/៣៖២=១/៦[72]។

**ឧទាហរណ៍ទី៣** ក្នុងករណីដែលលោក A មាននារី B ជាសហព័ទ្ធ ហើយគ្មានកូន។ ប៉ុន្តែលោក A នៅមានឪពុក និងម្តាយបង្កើតរបស់ខ្លួន។ ក្នុងករណីនេះ មាត្រា ១២៣០ ចំណុច ខ ត្រូវយកមកអនុវត្ត ដោយហេតុថាមានសន្តតិជន ផ្សេងពីឪពុក ម្តាយ នាំឲ្យចំណែកភាគបម្រុងដែលត្រូវធានាស្មើនឹងមួយភាគពីរ។ ហើយចំណែកភាគបម្រុងនៃសន្តតិជនម្នាក់ត្រូវទទួលបានតាមសមាមាត្រនៃចំណែកមត៌ករបស់ខ្លួន សហព័ទ្ធ ១/៣ ឪពុកម្តាយ ២/៣ នាំឲ្យចំណែកម្នាក់ៗស្មើ ១/៦ ស្មើៗគ្នា។

**ឧទាហរណ៍ទី៤** ក្នុងករណីដែលលោក A មិនមានបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់។ តែលោក A មានសហព័ទ្ធ និងបងប្អូនបង្កើត ៣នាក់។ ក្នុងករណីនេះភាគបម្រុងធានាចំពោះសន្តតិជនជាសហព័ទ្ធតែម្នាក់ប៉ុណ្ណោះ នាំឲ្យសហព័ទ្ធរបស់មតកជនទទួលបានចំណែក នៃភាគបម្រុង ស្មើនឹង ១/២ នៃមត៌ក។

## កថាភាគទី ២៖ ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាវិធានការមួយដើម្បីស្តារផលប្រយោជន៍របស់សន្តតិជនដែលមានសិទ្ធិលើភាគបម្រុង ឲ្យទទួលបាននូវសិទ្ធិរបស់ខ្លួនតាមកំណត់ច្បាប់។ ក្រមរដ្ឋប្បវេណី បានចែងពីការកំណត់ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារឲ្យកាត់បន្ថយបាន ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយ និងលំដាប់នៃការកាត់បន្ថយ។

### ១.ទ្រព្យដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង

[71] មាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណី

[72] មាត្រា ១២៣០ ចំណុច ក នៃក្រមរដ្ឋប្បវេណី

ភាគបម្រុង គឺជាចំណែកសមាមាត្រនៃមត៌កដែលមាន។ បើមូលដ្ឋាននៃទ្រព្យសម្បត្តិសម្រាប់ការគណនាភាគបម្រុងនេះ ត្រូវបានកម្រិតត្រឹមតែមត៌ក នោះអាចមានករណី មតកជនធ្វើប្រទានកម្មទ្រព្យសម្បត្តិយ៉ាងច្រើនមុនពេលស្លាប់ ដើម្បីជៀសវាងពីប្រព័ន្ធនៃ ភាគបម្រុងនេះបាន។ ហេតុនេះហើយ ការគណនាភាគបម្រុង ត្រូវរាប់បញ្ចូលនូវទ្រព្យ សម្បត្តិមួយចំនួន ដែលមានមុនពេលមរណភាពរបស់មតកជន ដូចជាប្រទានកម្ម និងតម្លៃនៃផលប្រយោជន៍ពិសេសជាដើម។

ការគណនាភាគបម្រុងត្រូវបានគណនា ដោយយកតម្លៃនៃផលប្រយោជន៍ពិសេស និងតម្លៃនៃប្រទានកម្ម ដែលជាមូលដ្ឋានក្នុងការគណនា បូកនិងទ្រព្យ សម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ហើយដកចំនួនប្រាក់សរុបនៃបំណុល (កាតព្វកិច្ច) និងការចំណាយលើបុណ្យសពចេញ។

| |
|---|
| ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង=ទ្រព្យពេលចាប់ផ្តើមសន្តតិកម្ម+តម្លៃនៃផលប្រយោជន៍ពិសេស+តម្លៃនៃប្រទានកម្ម-ចំនួនសរុបនៃកាតព្វកិច្ច |

អត្ថន័យនៃពាក្យគន្លឹះ

**-តម្លៃនៃផលប្រយោជន៍ពិសេស** គឺទ្រព្យដែលបុគ្គល (សន្តតិជន) បានទទួល ជាប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលជាអច្ច័យទានពីមតកជន[73]។

ឧទាហរណ៍៖ លោក A និងលោកស្រី B បានទិញផ្ទះមួយល្វែងតម្លៃ ៨០០០០ $ ឲ្យកូនស្រីទី ២ របស់គាត់ជាចំណងដៃអាពាហ៍ពិពាហ៍។ ផ្ទះដែលមានតម្លៃ ៨០០០០$ ជាតម្លៃនៃផលប្រយោជន៍ពិសេស ដែលត្រូវយកមកធ្វើជាមូលដ្ឋានក្នុងការគណនាភាគបម្រុង។

**<u>ចំណាំ៖</u>** ប្រទានកម្មដែលធ្វើឲ្យទៅសន្តតិជនជាតម្លៃនៃផលប្រយោជន៍ពិសេស។

**-ប្រទានកម្ម** គឺជាកិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។

ប្រទានកម្មដែលត្រូវយកមកគណនាភាគបម្រុង ត្រូវអនុលោមតាមមាត្រា ១២៣២ ក្រមរដ្ឋប្បវេណី គឺប្រទានកម្មដែលធ្វើឡើងក្នុងអំឡុងពេល ១ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម។

ឧទាហរណ៍៖ លោក A បានឲ្យទៅ ក្មួយស្រីនូវម៉ូតូមួយគ្រឿង តម្លៃ ១៥០០$ ជាការលើកទឹកចិត្តដល់នាងពេលដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ម៉ូតូមួយគ្រឿងតម្លៃ ១៥០០$ ជាប្រទានកម្ម។

[73] មាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណី

-**ទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម** គឺទ្រព្យជាក់ស្ដែងដែលបន្សល់ទុកដោយមតកជនក្រោយពេលទទួលមរណភាព។

**ឧទាហរណ៍៖** ទ្រព្យរបស់លោក A រួមមាន ផ្ទះមួយល្វែង តម្លៃ ១០០.០០០$ ឡានមួយគ្រឿង តម្លៃ ៣០០០០$ លុយក្នុងធនាគារ ១០០០០$ ក្នុងឆ្នាំចុងក្រោយដែលលោក A ឈឺគាត់បានលក់ឡានរបស់គាត់ និងដកប្រាក់ពីធនាគារទាំងអស់មកព្យាបាលជំងឺ ក្រោយមរណភាព ទ្រព្យរបស់លោក A នៅសល់តែផ្ទះមួយល្វែងតម្លៃ ១០០.០០០$ តែប៉ុណ្ណោះ ដូច្នេះទ្រព្យជាក់ស្ដែងក្រោយមរណភាព គឺ ផ្ទះមួយល្វែងតម្លៃ ១០០.០០០$ ដែលមូលដ្ឋានត្រូវយកមកគណនាភាគបម្រុង។

-**កាតព្វកិច្ច** គឺជាចំណងតាមផ្លូវច្បាប់ដែលចងបុគ្គលពីរនាក់ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា (កូនបំណុល) មានករណីកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀតដែលបានកំណត់ថា (ម្ចាស់បំណុល)។ កាតព្វកិច្ចនៅក្នុងករណីនេះ ជាកាតព្វកិច្ច ដែលមតកជនត្រូវទទួលខុសត្រូវនៅពេលគាត់ស្លាប់ រួមទាំងចំណាយសម្រាប់បុណ្យសព។

ឧទាហរណ៍៖ លោក A ជាពាណិជ្ជករម្នាក់ ដើម្បីពង្រីកមុខរបររបស់ខ្លួនលោក A បានខ្ចីប្រាក់ពីលោក D ចំនួន ៥០០០០$ ដោយដាក់បញ្ចាំដីរបស់ខ្លួនមួយកន្លែងនៅខេត្តសៀមរាបជាការធានាបំណុល។ ប្រាក់ ៥០០០០$ ជាកាតព្វកិច្ចដែលជាមូលដ្ឋានដែលត្រូវយកមកគណនាភាគបម្រុង។

**២.លំដាប់នៃការកាត់បន្ថយ**

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុង រួមមានអច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្ម[74]។ ដើម្បីយល់ដឹងថាតើការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងយ៉ាងដូចម្ដេចនោះ ច្បាប់ក៏បានកំណត់ពីលំដាប់នៃការកាត់បន្ថយផងដែរ។

ប្រទានកម្ម និងការទទួលផលប្រយោជន៍ពិសេស មិនអាចកាត់បន្ថយបានឡើយ ដរាបណាអច្ច័យទាន និងការកំណត់ចំណែកមត៌ក មិនទាន់បានកាត់បន្ថយជាមុននោះទេ[75]។

ជាគោលការណ៍ ប្រសិនបើមត៌កដែលមាននៅពេលចាប់ផ្ដើមសន្តតិកម្មមានគ្រប់គ្រាន់ក្នុងការកាត់បន្ថយដើម្បី បង្គ្រប់ភាគបម្រុងនោះ ប្រទានកម្ម និងការចាត់ចែងពិសេសរបស់មតកជននៅពេលនៅរស់មិនចាំបាច់លើកមកពិចារណាទេ។ ប៉ុន្តែ ក្នុងករណីដែលការកាត់បន្ថយមត៌កនាំឲ្យទៅជាការបំពានលើ ភាគបម្រុងដោយសារការធ្វើប្រទានកម្មនៅពេលនៅរស់ ហេតុដូច្នេះ ប្រទានកម្មក៏ជាកម្មវត្ថុនៃការកាត់បន្ថយដែរ។

**ក.លំដាប់នៃការកាត់បន្ថយអច្ច័យទាន និងការកំណត់ចំណែកមត៌កតាមមតកសាសន៍**

[74] មាត្រា ១២៣៣ នៃក្រមរដ្ឋប្បវេណី វាក្យខណ្ឌទី ១

[75] មាត្រា ១២៣៦ នៃក្រមរដ្ឋប្បវេណី

លំដាប់នៃការកាត់បន្ថយអច្ច័យទាន និងការកំណត់ចំណែកមត៌កតាមមតកសាសន៍មានពីរ[76]៖

ទី១៖ ការកាត់បន្ថយពីអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន។

ទី២៖ ការកាត់បន្ថយពីអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន។

មូលហេតុដែលនាំឲ្យមានការកាត់បន្ថយពីសន្តតិជនជាដំបូង គឺដោយសារតែសន្តតិជនត្រូវទទួលសន្តតិកម្មនូវ ឋានៈជាកូនបំណុលនៃអច្ច័យទានពីមតកជន ដូច្នេះ ជាបឋមត្រូវសម្រួលផ្ទៃក្នុងនៃសន្តតិជនជាមុនសិន ហើយប្រសិន បើមិនគ្រប់ទេ ទើបអាចកាត់បន្ថយពីអ្នកខាងក្រៅ។ ការកាត់បន្ថយអច្ច័យទាន គឺត្រូវធ្វើទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ។

ឧទាហរណ៍៖ នៅក្នុងមតកសាសន៍មានមត៌កចំនួន ២០,០០០ ដុល្លារ មតកជនបានសម្រេចធ្វើការបែងចែក ៤,០០០ ដុល្លារ ឲ្យទៅកូន A។ កូន B ទទួលបាន ៤,០០០ ដុល្លារ និងធ្វើអច្ច័យទានឲ្យទៅក្មួយ C ១១,០០០ ដុល្លារ។ ប្រាក់នៅសល់ ១,០០០ ដុល្លារ ឲ្យទៅភរិយា D។

តាមការគណនាភាគបម្រុង[77] ២០,០០០ × ១/២ × ១/៣= ៣,៣៣៣.៣៣

ទឹកប្រាក់ដែល D អាចធ្វើការទាមទារ គឺ: ៣,៣៣៣.៣៣ - ១,០០០= ២,៣៣៣.៣៣

ដូច្នេះ D ត្រូវទាមទារពី A & B ជាមុនសិន = ១,៣៣៣.៣៤

A = ៤,០០០ - ៣,៣៣៣.៣៣៣ = ៦៦៦.៦៧

B = ៤,០០០ - ៣,៣៣៣.៣៣ = ៦៦៦.៦៧

ចំណែកដែលនៅខ្វះ D អាចទាមទារបន្ថែមពី C = ១,០០០

**ខ.លំដាប់នៃការកាត់បន្ថយប្រទានកម្ម ឬផលប្រយោជន៍ពិសេស**

ការកាត់បន្ថយប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្ដើមពីប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មកត្រូវធ្វើចំពោះប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេស ដែលបានធ្វើមុនមកជាបន្តបន្ទាប់[78]។

[76] មាត្រា ១២៣៧ នៃក្រមរដ្ឋប្បវេណី

[77] មាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណី

[78] មាត្រា ១២៣៨ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី ១

ប៉ុន្តែបើការធ្វើប្រទានកម្ម ឬទទួលផលប្រយោជន៍ពិសេស លើសពី ២០ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធនូវការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន[79]។

**គ.ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង មិនត្រូវបំពានភាគបម្រុងរបស់សន្តតិជនដទៃ**

ទាំងការធ្វើប្រទានកម្ម និងការធ្វើអច្ច័យទាន ប្រសិនបើជនដែលទទួលនោះជាសន្តតិជន ហើយចំណែកមត៌ក របស់ពួកគេស្ថិតនៅក្នុងស្ថានភាពនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ការកាត់បន្ថយនេះត្រូវធ្វើឡើងដោយដកនូវ ភាគបម្រុងរបស់សន្តតិជននោះជាមុនសិន ដើម្បីកុំឲ្យភាគបម្រុងរបស់ពួកគេត្រូវបានបំពានដោយសារការកាត់បន្ថយនោះ[80] [81]។

ឧទាហរណ៍៖ មតកជន K មានសហព័ទ្ធ A ព្រមទាំងកូន B និង C។ កាលពី ១១ខែ មុនពេលទទួលមរណភាពមតកជនបាន ធ្វើប្រទានកម្មឲ្យ B ដើម្បីធ្វើជាទុនសម្រាប់មុខជំនួញចំនួន ១១០០ ដុល្លារ ហើយកន្លះឆ្នាំមុននឹងទទួលមរណភាពក៏បាន ធ្វើប្រទានកម្មឲ្យ A ចំនួន ៣០០ ដុល្លារ។ ជាលទ្ធផល មត៌កនៅសល់តែ ១០០ ដុល្លារ។ ក្នុងករណីនេះ ភាគបម្រុងរបស់ C គឺ ២៥០ ដុល្លារ (១,១០០ + ៣០០ + ១០០ × ១/២ ×១/៣) ប៉ុន្តែទោះបីជា C នឹងទាមទារពី A ដែលបានទទួលប្រទានកម្ម ក្រោយនោះកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ប៉ុន្តែអាចកាត់បន្ថយបានតែ ៥០ ដុល្លារ ប៉ុណ្ណោះ ព្រោះនឹងបំពានភាគបម្រុងរបស់គាត់។ ចំណែកនៅសល់ជាង ១០០ ដុល្លារ ទៀត C អាចទាមទារឲ្យកាត់បន្ថយពី B។

## កថាភាគទី ៣៖ ការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយ

### ១.អាជ្ញាយុកាល

សិទ្ធិទាមទារឲ្យកាត់បន្ថយត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ឆ្នាំ បានកន្លងហួស គិតចាប់ពីពេល ដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ។ សិទ្ធិទាមទារឲ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម[82]។

[79] មាត្រា ១២៣៨ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី ២
[80] មាត្រា ១២៣៣ នៃក្រមរដ្ឋប្បវេណី វាក្យខណ្ឌទី ២
[81] មាត្រា ១២៣៧ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី ២
[82] មាត្រា ១២៤៥ នៃក្រមរដ្ឋប្បវេណី

ការរលត់ដោយអាជ្ញាយុកាលនៃសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ[83]។

ចំពោះប្រទានកម្ម ក្នុងករណីដែលបានធ្វើប្រទានកម្ម ឬទទួលផលប្រយោជន៍ពិសេស លើសពី ២០ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន[84]។

**២.ការបោះបង់ភាគបម្រុង**

ភាគបម្រុងអាចបោះបង់ចោលទាំងអស់ ឬមួយផ្នែកបាន[85]។ ការបោះបង់ភាគបម្រុង គឺអាចធ្វើបានដោយការបង្ហាញឆន្ទៈតែម្ខាងចំពោះអ្នកមានកាតព្វកិច្ច។

ឧទាហរណ៍៖ ដូចជាការទទួលប្រាក់កំណត់មួយពីជនដែលមានកាតព្វកិច្ច ហើយជាថ្នូរ គឺត្រូវបោះបង់នូវភាគបម្រុងដែលនៅខ្វះ ជាដើម។

ចំណែកឯ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្តើមសន្តតិកម្មមានអានុភាព លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ[86]។ ការណ៍នេះ ដើម្បីកុំឲ្យមានការបោះបង់សិទ្ធិនេះជាមុន ដោយសារតែចាញ់អំណាចរបស់ឪពុកម្តាយ ប៉ុន្តែបើមាន ចាំបាច់ត្រូវមានការពិនិត្យតាងនាមជាអាណាព្យាបាលដោយតុលាការ។ តុលាការដែលទទួល ពាក្យសុំឲ្យអនុញ្ញាតនោះ ត្រូវធ្វើការវិនិច្ឆ័យដោយពិនិត្យមើល ថាតើការបោះបង់នោះជាឆន្ទៈពិតរបស់ជនដែលមានសិទ្ធិលើភាគបម្រុងឬទេ តើការបោះបង់នោះមានភាពសមហេតុសមផលដែរឬទេ តើចាំបាច់បោះបង់ឬទេ តើមានតម្លៃជាថ្នូរដែរឬទេ។

ម៉្យាងទៀត ទោះបីជាបានបោះបង់សិទ្ធិនេះ មុនពេលចាប់ផ្តើមសន្តតិកម្មដោយទទួលការអនុញ្ញាតពីតុលាការ ក៏ដោយ ក៏អ្នកមានសិទ្ធិលើភាគបម្រុងនោះអាចដាក់ពាក្យសុំឲ្យតុលាការលុបចោលការអនុញ្ញាតមុននោះបាន នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរក្រោយពេលបោះបង់សិទ្ធិនោះ។

[83] មាត្រា ១២៤៧ នៃក្រមរដ្ឋប្បវេណី

[84] មាត្រា ១២៣៨ នៃក្រមរដ្ឋប្បវេណី

[85] មាត្រា ១២៤៦ នៃក្រមរដ្ឋប្បវេណី វាក្យខណ្ឌទី ១

[86] មាត្រា ១២៤៦ នៃក្រមរដ្ឋប្បវេណី វាក្យខណ្ឌទី ២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយឥតប្រកែកបាន គ្រប់វិធានច្បាប់ទាំងអស់ពុំត្រូវមានឧបនិស្ស័យត្រឹមតែជាវិធាន លើក្រដាសនោះទេ ប៉ុន្តែទាមទារឲ្យអាចយកទៅអនុវត្តក្នុងសង្គមជាតិជាក់ស្តែងបានទៀតផង ពីព្រោះថារាល់វិធានច្បាប់ទាំងអស់មានគោលដៅតែមួយគត់ដូចគ្នា គឺបញ្ចៀសជម្លោះក្នុងសង្គម (រក្សាសណ្តាប់ធ្នាប់សាធារណៈ)។ផ្ទុយទៅវិញ ការសិក្សាលើប្រធានបទ «សន្តតិកម្មតាមច្បាប់» ដែលបានបង្ហាញខាងលើនេះ គឺពិតណាស់គ្រាន់តែជាការស្វែងយល់តែលើ ផ្នែកទ្រឹស្តីមួយដោយផ្អែកជាសំខាន់តែទៅលើ វិធានច្បាប់ ដែលមានប៉ុណ្ណោះ ពីព្រោះថានៅក្នុងបរិបទនៃសង្គមសព្វថ្ងៃ រាល់ការអនុវត្តណាមួយតាមវិធាននេះ នៅមានកម្រិតនូវឡើយហើយថែមទាំងពិបាកស្វែងរកឲ្យដឹងទៀតផង។ ការណ៍នេះ គឺជាចំណុចខ្សោយមួយ នៃការសិក្សារបស់យើងលើប្រធានបទនេះ។ ដូចនេះ ការសិក្សាលើប្រធានបទនេះ និងនាពេលនេះ អាចផ្តល់អត្ថប្រយោជន៍ឲ្យយើងបានត្រឹមតែជាការស្វែងយល់ផ្នែកទ្រឹស្តីមួយប៉ុណ្ណោះ។ ទោះបីជាយ៉ាងនេះក្តី សន្តតិកម្មដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទរឿងក្តីស្នងមត៌ក ព្រោះរឿង កើត ឈឺ ចាស់ ស្លាប់ គឺជារឿងដែលមនុស្សម្នាក់ៗត្រូវឆ្លងកាត់ហើយបើកាលណាមានការស្លាប់រឿងសន្តតិកម្មគឺត្រូវតែចូលមកពាក់ព័ន្ធជាដាច់ខាត់។ អាស្រ័យហេតុនេះប្រជាពលរដ្ឋទាំងឡាយគប្បីធ្វើការស្វែងយល់អំពីវាឲ្យបានច្រើនដើម្បីទុកជាប្រយោជន៍ទៅថ្ងៃមុខ។

ទោះបីជាយ៉ាងនេះក្តី ការតាក់តែងច្បាប់នីមួយៗមិនអាចបំពេញតម្រូវការ និងសមស្របតាមបរិបទនៃការអនុវត្តល្អឥតខ្ចោះនោះទេ ទោះបីជាការតាក់តែងនោះមានភាពល្អយ៉ាងណាក្តីនាពេលតាក់តែងនោះ ក៏មិនមានន័យថា ការអនុវត្តរបស់វាមានប្រសិទ្ធភាពគ្រប់ពេលវេលា និងកាលៈទេសៈនោះដែរ ព្រោះតែបរិបទសង្គមតែងតែមានការអភិវឌ្ឍន៍ទៅមុខជានិច្ច ធ្វើឲ្យការតាក់តែងច្បាប់ក៏ត្រូវទាមទារឲ្យមានការអភិវឌ្ឍន៍ឲ្យទាន់សង្គមផងដែរ។

សរុបរួមមកសន្តតិកម្មតាមច្បាប់នេះបានជួយធ្វើឲ្យការបែងចែកក៏ដូចជាការគ្រប់គ្រងមត៌ករបស់មតកជនមានសមភាព និងយុត្តិធម៌ ដោយធ្វើឲ្យវិវាទទាក់ទងនឹងសន្តតិកម្មមានការថយចុះដើម្បីឲ្យប្រជាពលរដ្ឋនិងរាជរដ្ឋាភិបាលផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍ប្រទេសជាតិយើងឲ្យកាន់តែមានភាពរីកចម្រើននិងរុងរឿងបន្ថែមទៀត។ជាការពិតណាស់ចំណុចសំខាន់ពិតប្រាកដនោះនូវតែជាការចូលរួមចំណែករបស់ប្រជាពលរដ្ឋដដែលដូច្នេះក្នុងកិត្តិយសជាកូនខ្មែរទាំងអស់គ្នាគប្បីស្វែងយល់អំពីផ្នែកនេះទុកជាចំណេះដឹងនិងផលប្រយោជន៍នាពេលខាងមុខ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីយើងខ្ញុំបានបកស្រាយនូវប្រធានបទខាងលើរួចមកហើយ យើងអាចសន្និដ្ឋានបានថាបញ្ញត្តិមាត្រាទាំងឡាយដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការយកមកអនុវត្តជាក់ស្តែង ក្នុងព្រះរាជាណាចក្រកម្ពុជានាពេលនេះ ប៉ុន្តែប្រសិនបើក្រឡេកមើលអនាគតវិញ សង្គមនឹងមានការផ្លាស់ប្តូរបរិបទយ៉ាងច្រើនទៅមុខទៀត ជាហេតុដែលតម្រូវឲ្យមានការកែតម្រូវច្បាប់ និងបទប្បញ្ញត្តិនានាឲ្យមានភាពសមស្របនឹងការវិវឌ្ឍរបស់សង្គម។

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ យើងខ្ញុំសូមចូលរួមជាយោបល់ និងអនុសាសន៍មួយចំនួនដូចខាងក្រោមដើម្បីចូលរួមជាចំណែកមួយ ក្នុងការធ្វើឲ្យប្រសើរឡើងនូវសន្តតិកម្ម នៃប្រទេសកម្ពុជា។ យើងខ្ញុំ សូមឲ្យស្ថាប័នផ្សេងៗដែលទាក់ទងទៅនឹងវិស័យច្បាប់ ជាពិសេសស្ថាប័ននីតិបញ្ញត្តិ ពិនិត្យ និងអនុម័តច្បាប់ ដើម្បីឲ្យតាមទាន់នូវការវិវឌ្ឍន៍ប្រែប្រួលនៃសង្គម។ ជាពិសេសទៅទៀត គឺយើងសូមធ្វើការអំពាវនាវដល់អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ រួមទាំងរាជរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយនូវបទប្បញ្ញត្តិច្បាប់ផ្សេងៗជាពិសេសទាក់ទងនឹងសន្តតិកម្ម ដើម្បីឲ្យប្រជាពលរដ្ឋមានការជ្រួតជ្រាប និងយល់ដឹងក្នុងន័យចូលរួមកាត់បន្ថយ និងលុបបំបាត់ចោលនូវទំនាស់ផ្សេងៗនៅក្នុងសង្គមគ្រួសាររួមទាំងសង្គមជាតិ ដោយហេតុថាសង្គមដែលមានការអភិវឌ្ឍន៍អាស្រ័យទៅលើចំណេះដឹង និងការអនុវត្តរបស់ប្រជាជន។ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋទៀតសោតក៏ត្រូវស្វែងយល់នូវព័ត៌មានផ្សេងៗទាក់ទងនឹងបញ្ញត្តិច្បាប់ ដើម្បីជាការយល់ដឹងមុននឹងសម្រេចចិត្តប្តឹងផ្តល់គ្នា ជាពិសេសក្នុងរង្វង់គ្រួសារខ្លួន ដើម្បីតែទទួលបាននូវមត៌កតែប៉ុណ្ណោះ ដោយគ្មានការយោគយល់ អធ្យាស្រ័យគ្នាក្នុងរង្វង់គ្រួសាររបស់ខ្លួន។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការបង្ហាញពីទឹកចិត្តក្នុងការត្រួសត្រាយផ្លូវ ក៏ដូចជាសំណូមពរដល់ស្ថាប័នតុលាការ ពិសេសប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា ចូលរួមអនុវត្ត និងលើកតម្កើងប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួនឲ្យមានដំណើរការរលូនទៅមុខឥតដាច់។

ជាចុងបញ្ចប់ ឆ្លងតាមរយៈការស្រាវជ្រាវ សន្តតិកម្មតាមច្បាប់ ពិតជាមានអត្ថប្រយោជន៍ខ្លាំងណាស់នៅក្នុងរបបសន្តតិកម្ម ក៏ដូចជាចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ដើម្បីអនុវត្តនាពេលបច្ចុប្បន្ន និងនាថ្ងៃអនាគត។ ត្បិតតែអនុសាសន៍ខាងលើមានភាពមិនគ្រប់គ្រាន់ និងស៊ីជម្រៅក៏ដោយ ក៏វាអាចជាកត្តាមួយជួយជម្រុញដល់ ការចូលរួមកាត់បន្ថយនូវវិវាទផ្សេងៗ ដែលទាក់ទងទៅនឹងការបែងចែកមត៌ករបស់មតកជន រួមទាំងធ្វើឲ្យមានភាពសុខសាន្ត និងសុខដុមរមនានៅក្នុងសង្គមគ្រួសារ និងសង្គមជាតិផងដែរ។

# ឯកសារយោង

# ឯកសារយោង

## I. ច្បាប់ និងបទប្បញ្ញត្តិ

- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
- អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០០
- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

## II. សៀវភៅ

- សៀវភៅ សន្តតិកម្ម រៀបរៀងដោយ មេធាវី«អ៊ីវ ប៉ូលី» ឆ្នាំ ២០១០
- សៀវភៅ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨ និង៩ នៃក្រសួងយុត្តិធម៌
- សៀវភៅ ក្រមរដ្ឋប្បវេណី ភាគទី ៦ ដែលគ្របដណ្តប់លើ មូលដ្ឋាននៃញាតិ និងសន្តតិកម្ម បង្កើតឡើងដោយសមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ឧបត្ថម្ភគាំទ្រដោយ JICA និង ICD បោះពុម្ពលើកទី ១ នៅក្នុងខែ មីនា ឆ្នាំ ២០១២
- សៀវភៅ មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី ១ ដែលជាសមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការរបស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA។
- សៀវភៅ មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី ៣ ដែលជាសមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការរបស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA។
- សៀវភៅ សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ១-៣ រៀបរៀងដោយ ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាជីវៈតុលាការ ឆ្នាំ ២០១៧
- នីតិមត៌ក រៀបរៀងដោយ សាស្ត្រាចារ្យ ចាំង ស៊ីណាត
- ឯកសារ វិភាគទានច្បាប់ ស្តីពី ការបែងចែកមត៌ក
- ឯកសារ សិក្ខាសាលា ស្តីពីសន្តតិកម្ម រៀបរៀងដោយសាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌ Ms.MIURA YASUKO

# ឧបសម្ព័ន្ធ